## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **គៀត ចាន់រដ្ឋា**

**ក. អ៊ុង សុគន្ធា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ:

ជំនាន់ទី ៨

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# អំណរគុណ

ជាបឋម ខ្ញុំបាទឈ្មោះ **គៀត ចាន់រដ្ឋា** និង នាងខ្ញុំ **អ៊ុំខ សុគន្ធា** សូមគោរព និងជម្រាបសួរដល់សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍ដល់មិត្តសិស្ស និស្សិត អ្នកស្រាវជ្រាវទាំងអស់ជាទីរាប់អាន។

ក្នុងនាមជានិស្សិតដែលកំពុងធ្វើការសិក្សាផ្នែក រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ យើងខ្ញុំទាំងពីរនាក់បានរៀបចំចងក្រង នូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រ ដែលមានប្រធានបទក្រោមចំណងជើងថា **អភិបាលកិច្ចល្អនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ។ ការសិក្សានូវប្រធានបទនេះដោយហេតុថា អភិបាលកិច្ចល្អ ត្រូវបានអនុវត្តយ៉ាងទូលាយនៅក្នុងប្រទេសកម្ពុជាទាំងស្ថាប័នជាតិ ក៏ដូចជាស្ថាប័នផ្សេងៗផងដែរ។ ក្នុងនោះផងដែរក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏បានធ្វើការងារមួយចំនួន ដែលមានលក្ខណៈសមស្របទៅនឹងគោលការណ៍នៃអភិបាលកិច្ចល្អផងដែរ ប៉ុន្តែមិនទាន់មានស្នាដៃណាធ្វើការសិក្សា ទៅលើកិច្ចការទាំងនោះព្រមទាំងស្វែងរកនូវបញ្ហាប្រឈមនានាដែលក្រុមប្រឹក្សានោះ បានជួបប្រទះនោះទេ ហេតុនេះហើយទើបបានជាយើងខ្ញុំ ខិតខំធ្វើការសិក្សាស្រាវជ្រាវធ្វើយ៉ាងណា រំលេចឡើងនូវភាពល្អប្រសើរនៃការអនុវត្តការងាររបស់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងបញ្ហាប្រឈមនានាដែលក្រុមប្រឹក្សានេះបានជួបប្រទះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សានេះនឹងរួមចំណែកយ៉ាងសំខាន់នៅក្នុងការជំរុញ ឱ្យគ្រប់ស្ថាប័នទាំងឡាយនៅកម្ពុជា ប្រើប្រាស់នូវគោលការណ៍អភិបាលកិច្ចល្អសម្រាប់ធ្វើឱ្យការអនុវត្តកិច្ចការងាររបស់ខ្លួនប្រកបដោយភាពល្អប្រសើរទោះតិចក្តីច្រើនក្តី ហើយវាក៏ជាឯកសារស្រាវជ្រាវថ្មីមួយ ដែលអាចបំពេញនូវតម្រូវការរបស់អ្នកសិក្សាទាំងឡាយដែល កំពុងជួបប្រទះនូវ កង្វះខាតឯកសារនាពេលបច្ចុប្បន្ននេះ។ យើងខ្ញុំក៏សូមខន្តីអភ័យទោសជាមុនផងដែរចំពោះកំហុសឆ្គងទាំងឡាយដែលកើតមាននៅក្នុងសារណាមួយនេះ ហើយយើងខ្ញុំក៏រង់ចាំទទួលនូវការរិះគន់ពីសំណាក់មិត្តអ្នកអាន និស្សិត ក៏ដូចជាសាស្ត្រាចារ្យទាំងអស់គ្រប់ពេលវេលា។

ជាទីបញ្ចប់នេះយើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន និស្សិត ក៏ដូចជាសាស្ត្រាចារ្យទាំងអស់ឱ្យបានជួបប្រទះតែសេចក្តីសុខ និងសុភមង្គល គ្រប់ពេលវេលាកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **គៀត ចាន់រដ្ឋា** និង នាងខ្ញុំ **អ៊ុំខ សុគន្ធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

-អ្នកម្តាយ **ឃ្លាំខ ផល្លា** លោកឪពុក **អឿ ចិត្រា** និងអ្នកម្តាយ **អ៊ុំ សារ៉េត** លោកឪពុក **អ៊ុំខ ឈឹម** ដែលបានផ្តល់កំណើត ចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ប្រកបទៅដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងសព្វគ្រប់បែបយ៉ាង ទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឱ្យកូនបានមកសិក្សារៀនសូត្ររហូតមានចំណេះវិជ្ជារហូតមកដល់ថ្ងៃនេះ។

-បណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកក្នុងការបង្ហាត់បង្រៀន ដើម្បីផ្តល់ជាការណែនាំដល់យើងខ្ញុំក្នុងការសរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សានេះឡើង។

-ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ និងសមាជិកទាំងអស់ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានអនុញ្ញាត និងជួយជ្រោមជ្រែងឱ្យយើងខ្ញុំបានចុះធ្វើការស្រាវជ្រាវឯកសារនានាដែលទាក់ទងទៅនឹងប្រធានបទនេះ។

-លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ទាំងអស់ដែលបានបង្រៀនយើងខ្ញុំទាំងពីរ តាំងពីចាប់ផ្តើមការសិក្សារហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដែលបានចំណាយកម្លាំងកាយ និងកម្លាំងចិត្តក្នុងការអប់រំទូន្មាន ប្រៀនប្រដៅ ផ្តល់ចំណេះវិជ្ជាដល់យើងខ្ញុំរហូតមកដល់ថ្ងៃនេះ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរសុខសួស្តីជូនដល់ អ្នកម្តាយ និងលោកឪពុក ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និង អ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមឱ្យជួបប្រទះតែជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យប្រកបតែនឹងពុទ្ធពរទាំង បួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**អារម្ភកថា** ..................................................... i
**សេចក្តីថ្លែងអំណរគុណ** ..................................................... ii
**មាតិកា** ..................................................... iii
**បញ្ជីអក្សរកាត់** ..................................................... vi
**សេចក្តីផ្តើម** ..................................................... ១
**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ..................................................... ១
**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ..................................................... ២
**៣. គោលបំណងនៃការស្រាវជ្រាវ** ..................................................... ២
**៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ..................................................... ៣
**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ** ..................................................... ៤
**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ..................................................... ៤
**ជំពូកទី ១ គោលការណ៍ទូទៅនៃអភិបាលកិច្ចល្អ** ..................................................... ៦
១.១. និយមន័យ ..................................................... ៦
១.២. គោលការណ៍នៃអភិបាលកិច្ចល្អ ..................................................... ៧
១.២.១. គោលការណ៍នៃអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលកម្ពុជា ..................................................... ៨
ក. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ..................................................... ៨
ខ. កំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ ..................................................... ៩
គ. កំណែទម្រង់រដ្ឋបាលសាធារណៈ ..................................................... ៩
ឃ. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ..................................................... ១០
១.២.២. គោលការណ៍នៃអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ ..................................................... ១០
ក. ការចូលរួម ..................................................... ១០
ខ. នីតិរដ្ឋ ..................................................... ១១
គ. តម្លាភាព ..................................................... ១១
ឃ. ការព្រមព្រៀងឯកភាពគ្នា ..................................................... ១២
ង. សមធម៌ ..................................................... ១២

ច. ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ........................................................................១២
ឆ. គណនេយ្យភាព ........................................................................................ ១៣
ជ. ការឆ្លើយតប.............................................................................................. ១៣
ឈ. ចក្ខុវិស័យជាយុទ្ធសាស្ត្រ..........................................................................១៤
១.២.៣. គោលការណ៍អភិបាលកិច្ចល្អរបស់ធនាគារពិភពលោក.........................១៤
ក. ការគ្រប់គ្រងវិស័យសាធារណៈ.....................................................................១៤
ខ. គណនេយ្យភាព .........................................................................................១៥
គ. ក្របខណ្ឌច្បាប់សម្រាប់ការអភិវឌ្ឍ..........................................................១៥
ឃ. តម្លាភាព និងព័ត៌មាន .............................................................................១៥
**ជំពូកទី ២ សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**........................................................................... ១៦
២.១. ប្រវត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌......................................១៦
២.២. សមត្ថកិច្ច និងភារកិច្ចរបស់ ក.ស.វ............................................................ ១៧
២.៣. មុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ...............................១៨
២.៤. មុខងារ និងភារកិច្ចរបស់ផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន ក.ស.វ..........១៩
២.៤.១. ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ.......................................................២០
២.៤.២. ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ...................................................................២០
២.៤.៣. ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌............២១
២.៤.៤. ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេត .........................................................២១
២.៤.៥. ផ្នែកលិខិតបទដ្ឋានគតិយុត្ត ............................................................... ២២
២.៤.៦. ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន................................២៣
២.៤.៧. ផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ .........................................២៣
២.៥. សមិទ្ធផល និងស្នាដៃរបស់ ក.ស.វ.............................................................២៤
២.៥.១. សកម្មភាព និងការងាររបស់ ក.ស.វ. ប្រចាំខែ ធ្នូ ឆ្នាំ២០១៤...................២៤
ក. សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ..........................................................២៤
ខ. កិច្ចប្រជុំត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ .........................................................................២៧

២.៦. ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌....................................២៧
២.៦.១. ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ ២០១៤ ..........២៨
ក. ការវិភាគស្ថានភាពសេដ្ឋកិច្ច.................................................................២៨
ខ. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សង្គមកិច្ច និងវប្បធម៌..............២៩
២.៧. ទស្សនៈវិស័យរបស់ ក.ស.វ. ចំពោះសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌............ ៣១
**ជំពូកទី ៣ ការវិភាគលើការអនុវត្តការងាររបស់ ក.ស.វ.** .................... ៣៣
៣.១. ការអនុវត្តការងារនៃ ក.ស.វ. ................................................................... ៣៣
៣.២. បញ្ហាប្រឈម ........................................................................................ ៣៦
៣.៣. ដំណោះស្រាយ ...................................................................................... ៣៧
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ............................................................. ៣៩
១. សេចក្តីសន្និដ្ឋាន ........................................................................................ ៣៩
២. អនុសាសន៍...........................................................................................៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ក.ស.វ. ៖ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ក.ស.ស.ស. ៖ ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- វិធីសាស្រ្ត RIA ៖ វិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ADB ៖ ធនាគារអភិវឌ្ឍន៍អាស៊ី
- RIA ៖ Regulatory Impact Assessment
  (ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត)

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសមួយ ដែលធ្លាប់បានទទួលរងនូវ វិនាសកម្មពីសង្គ្រាមស៊ីវិលដែលបានអូសបន្លាយអស់រយៈពេលជាច្រើនទស្សវត្សរ៍។ ក្នុងកំឡុងពេលនៃវិនាសកម្មនេះបានកើតឡើងប្រទេសកម្ពុជា បានបាត់បង់នូវធនធានមនុស្ស យ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលធនធានមនុស្សទាំងនេះត្រូវបានគេចាត់ទុកថា ជាចលករមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩២ ប្រទេសកម្ពុជា បានស្គាល់នូវការបង្រួបបង្រួមជាតិមួយ ដែលបានឈានទៅដល់ការបោះឆ្នោតជាតិជាសកលនៅក្នុងឆ្នាំ ១៩៩៣ ដែលរៀបចំដោយ ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលហៅកាត់ថា UNTAC (អ៊ុនតាក់)។ បន្ទាប់ពីការបោះឆ្នោតនោះបានប្រព្រឹត្តទៅដោយមានលក្ខណៈល្អប្រសើររួចមកប្រទេសកម្ពុជា បានទទួលនូវរាជរដ្ឋាភិបាលស្របច្បាប់មួយ ដែលបើកផ្លូវឱ្យបណ្ដាប្រទេសអ្នកផ្ដល់ជំនួយនានា មានលទ្ធភាពគ្រប់គ្រាន់ នៅក្នុងការផ្ដល់ជំនួយនានា ដល់កម្ពុជារាប់ទាំងជំនួយជាថវិកា ក៏ដូចជាជំនួយបច្ចេកទេសនានា ដើម្បីធ្វើការអភិវឌ្ឍប្រទេសកម្ពុជាសំដៅធ្វើឱ្យកម្ពុជាមានមុខមាត់ នៅលើឆាកអន្តរជាតិ ក៏ដូចជាធ្វើឱ្យមានភាពកាន់តែប្រសើរឡើងនូវដំណើរការការងារនានារបស់ស្ថាប័នរដ្ឋផងដែរ។

ដោយមានការជឿជាក់ទៅលើអភិបាលកិច្ចល្អ ដែលជាយន្តការមួយយ៉ាងពិសេសក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្ដល់ ក៏ដូចជាការគ្រប់គ្រងនូវដំណើរការការងារនានារបស់រដ្ឋនោះ នៅក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកអភិបាលកិច្ចល្អជា ស្នូលនៃគោលនយោបាយរបស់រដ្ឋក្នុងការកែទម្រង់នានាផងដែរ។ តួយ៉ាងដូចជានៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៥ បានកំណត់យក អភិបាលកិច្ចល្អ ជាស្នូលនៅក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តគោលនយោបាយរបស់ខ្លួន ហើយរដ្ឋបានចាត់ទុកថា អភិបាលកិច្ចល្អអាចនឹងធ្វើឱ្យប្រសើរឡើងនូវ ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ ក៏ដូចជាការគ្រប់គ្រងធនធាននានាផងដែរ[1]។ ក្នុងការគ្រប់គ្រងនិងធ្វើឱ្យប្រសើរឡើង នូវដំណើរការនៃស្ថាប័ននានារបស់រដ្ឋដែលមានស្រាប់រាជរដ្ឋាភិបាលកម្ពុជា ក៏បានសម្រេចបង្កើតឡើងនូវក្រុមប្រឹក្សានានា ដើម្បីជួយសម្រួលដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រង ពិនិត្យ និងពិគ្រោះយោបល់នានាពាក់ព័ន្ធទៅនឹងកិច្ចការរបស់

[1] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា* (ភ្នំពេញ, ២០១៣), ៤។

ស្ថាប័ននានារបស់រដ្ឋ។ តួយ៉ាងដូចជាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានឈ្មោះហៅកាត់ថា ក.ស.វ.[2]។

ក្នុងការបង្កើតនូវក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នេះគឺពិតជាបានជួយសម្រួលយ៉ាងច្រើននូវកិច្ចការងារនានារបស់ រាជរដ្ឋាភិបាលក៏ដូចជាស្ថាប័នមួយចំនួន ដែលស្ថិតនៅក្រោមចំណុះរាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩។ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាយន្តការអមទីស្តីការគណៈរដ្ឋមន្ត្រី[3] ដែលមានភារកិច្ច ពិនិត្យ តាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិក្សាស្រាវជ្រាវបញ្ហាប្រឈម និងពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ហើយលើកយោបល់នានាជូនរាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះដែរ ការបង្កើតឱ្យមានអភិបាលកិច្ចល្អនៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏ធ្វើឱ្យក្រុមប្រឹក្សានេះកាន់តែមានដំណើរការការងារល្អ និងមានប្រសិទ្ធភាពការងារខ្ពស់ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយ ក.ស.វ. ជាក្រុមប្រឹក្សាចំណុះឱ្យទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ហើយទើបតែត្រូវបានបង្កើតឡើងនាឆ្នាំ ២០០៩ ដូចនេះការសិក្សាទៅលើអភិបាលកិច្ចល្អនៅក្នុងស្ថាប័នមួយនេះ ពិតជាមានការចាំបាច់។ នៅក្នុងការស្រាវជ្រាវនេះ ក៏មានចំណោទបញ្ហាមួយចំនួនដែលត្រូវបានលើកយកមកពិភាក្សាដូចជា៖

-តើដំណើរការនៃការអនុវត្តអភិបាលកិច្ចល្អរបស់ ក.ស.វ. ប្រព្រឹត្តទៅយ៉ាងណាខ្លះ?

-ហើយមានបញ្ហាប្រឈមអ្វីខ្លះ ដែលរាំងស្ទះដល់ដំណើរការងារនៃ ក.ស.វ. ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក.ស.វ. ជាក្រុមប្រឹក្សាដែលមានតួនាទីដ៏សំខាន់មួយ ក្នុងការជួយជំរុញឱ្យមានការអភិវឌ្ឍទៅលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដោយក្រុមប្រឹក្សានេះធ្វើការតាមដាននូវរាល់ស្ថានភាពសេដ្ឋកិច្ច និងធ្វើការប្រមូលនូវទិន្នន័យ ពីគ្រប់ក្រសួងដែលពាក់ព័ន្ធដើម្បីធ្វើការវាយតម្លៃថា

[2] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ នស/រកត/០២០៩/១៧៣, ១៧ កុម្ភៈ ២០០៩, មាត្រា១។

[3] ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ នស/រកត/០២០៩/១៧៣, ១៧ កុម្ភៈ ២០០៩, មាត្រា១។

តើស្ថានភាពសេដ្ឋកិច្ចសព្វថ្ងៃនេះមានការកើនឡើង ឬមួយក៏ថយចុះ ព្រមទាំងធ្វើការវិភាគលើតម្លៃនៃទំនិញគ្រប់ប្រភេទថែមទៀតផង។ ដោយ ក.ស.វ. នេះ ជាក្រុមប្រឹក្សាមួយដែលទើបតែនឹងបង្កើតដូច្នេះហើយសកម្មភាពការងារគឺមានលក្ខណៈថ្មីនៅឡើយ។ ការសិក្សាទៅលើប្រធានបទនេះគឺមានគោលបំណងដើម្បីបង្កើននូវការយល់ដឹងអំពី ការអនុវត្តការងាររបស់ ក.ស.វ. ឱ្យបានច្បាស់លាស់ និងបានចូលរួមដោយប្រយោលក្នុងការជួយពន្លឿននូវ អភិបាលកិច្ចល្អនៅក្នុងសកម្មភាពការងាររបស់ ក.ស.វ. ឱ្យមានលក្ខណៈល្អប្រសើរឡើង។

ចំពោះគោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទនេះត្រូវបានផ្តោតជាសំខាន់ទៅលើះ

- ការសិក្សាលើការអនុវត្តការងាររបស់ ក.ស.វ. ថាតើមានលក្ខណៈដូចអ្វីដែលជាចំណុចនៃគោលការណ៍របស់អភិបាលកិច្ចល្អឬយ៉ាងណា។
- បញ្ហាប្រឈមនូវក្នុងការអនុវត្តការងាររបស់ ក.ស.វ. ។
- ការលើកឡើងនូវសំណូមពរមួយចំនួនដើម្បីឱ្យ ក.ស.វ. ធ្វើការកែលម្អនូវចំណុចដែលមានការខ្វះខាតមួយចំនួន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាមួយជាធម្មតារមែងមាននូវដែនកំណត់ និងវិសាលភាព ដូចគ្នានេះផងដែរ នៅក្នុងការសិក្សាទៅលើប្រធានបទ អភិបាលកិច្ចល្អនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នេះដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ គឺធ្វើការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តីនៃអភិបាលកិច្ចល្អ លិខិតបទដ្ឋានគតិយុត្តនានា ដូចជាច្បាប់ដែលបានដាក់ឱ្យអនុវត្ត និងនៅជាធរមានពាក់ព័ន្ធទៅនឹងអភិបាលកិច្ចល្អ។ ក្នុងការឱ្យនិយមន័យទៅលើអភិបាលកិច្ចល្អ ក៏ផ្អែកទៅលើប្រភពជាក់លាក់មួយចំនួនដែលបានផ្តល់និយមន័យខុសៗពីគ្នា ប៉ុន្តែអ្វីដែលបានផ្តោតជាចម្បងនោះគឺទ្រឹស្តីរួមរបស់ក្រសួងមហាផ្ទៃដែលមាន ឥទ្ធិពលក្នុងការអនុវត្ត ក៏ដូចជាសមស្របនឹងបរិបទនៃសង្គមកម្ពុជាផងដែរ។ ការសិក្សានេះក៏ធ្វើការសិក្សាទៅលើរចនាសម្ព័ន្ធទាំងមូលនៃ ក.ស.វ. ដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់នូវដំណើរការការងារ ក៏ដូចជាការប្រព្រឹត្តទៅនៃអង្គភាពនេះផងដែរ។ ការសិក្សានេះនឹងធ្វើឡើងដោយផ្តោតទៅលើសកម្មភាពការងារដែល ក.ស.វ. បានធ្វើនៅក្នុងខែធ្នូ ឆ្នាំ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ ដោយឡែកនៅក្នុងផ្នែកចុងក្រោយ នៃការសិក្សានេះនឹងធ្វើឡើងតាមរយៈការវិភាគនូវ ចំណុចទាំង ៩ នៃទ្រឹស្តីអភិបាលកិច្ចល្អ របស់ក្រសួងមហាផ្ទៃដែលជាទ្រឹស្តីចម្បងក្នុងការស្រាវជ្រាវនេះ ដោយផ្សារភ្ជាប់នូវសកម្មភាពការងារទាំងឡាយរបស់

ក.ស.វ. ដើម្បីធ្វើការវិភាគ ស្វែងរកបញ្ហាប្រឈមនានា ព្រមទាំងផ្តល់ជាអនុសាសន៍ដើម្បីជាការកែលម្អដល់ចំណុចដែលមានការខ្វះខាតមួយចំនួនផងដែរ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានូវប្រធានបទនេះត្រូវបានធ្វើឡើងតាមរយៈការយោង ពីប្រភពឯកសារមួយចំនួនដូចជាសៀវភៅនៅក្នុងបណ្ណាល័យ និងបណ្ណាគារមួយចំនួន ព្រមទាំងធ្វើការប្រមូលទិន្នន័យដែលបានមកពីប្រភពដែលពាក់ព័ន្ធ ដើម្បីយកមកធ្វើការវិភាគវែកញែក យ៉ាងច្បាស់លាស់ទៅលើប្រភពទិន្នន័យទាំងនោះ។ ចំណែកឯការចងក្រងនូវសារណាបញ្ចប់ការសិក្សានេះគឺចាំបាច់ត្រូវបែងចែកនូវប្រភេទទិន្នន័យជាពីរគឺ:

### ទិន្នន័យចម្បង

ចំពោះទិន្នន័យចម្បងនេះត្រូវបានចងក្រងឡើង តាមរយៈការចុះទៅសិក្សាស្រាវជ្រាវនៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដោយផ្ទាល់។ ហើយបានធ្វើការប្រមូលនូវទិន្នន័យឯកសារសកម្មភាពការងាររបស់ក្រុមប្រឹក្សានេះ និងសមិទ្ធផលនានា ព្រមទាំងបានចុះទៅសាកសួរព័ត៌មានមួយចំនួនពីថ្នាក់ដឹកនាំនៃ ក.ស.វ. ដោយផ្ទាល់ផងដែរ។

### ទិន្នន័យបន្ទាប់បន្សំ

ចំពោះទិន្នន័យបន្ទាប់បន្សំវិញ គឺត្រូវបានរៀបចំឡើងដោយបានប្រមូលនូវឯកសារពាក់ព័ន្ធផ្សេងៗដែលបានសិក្សាស្រាវជ្រាវនៅក្នុង បណ្ណាល័យច្បាប់ និងតាមបណ្ណាល័យសាធារណៈនានារួមផ្សំទាំងគេហទំព័ររបស់រដ្ឋក៏ដូចជាស្ថាប័ននានា ជាពិសេសគេហទំព័រនៃ ក.ស.វ. នៅលើប្រព័ន្ធអ៊ីនធឺណិត និងឯកសារផ្សេងៗមួយចំនួនទៀតផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការធ្វើឱ្យកម្រងស្នាដៃស្រាវជ្រាវមួយនេះប្រកបទៅដោយលទ្ធផលល្អប្រសើរ និងមានរបៀបរៀបរយនោះ គឺចាំបាច់ណាស់ក្នុងការបង្កើតនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវមួយប្រកបដោយភាពច្បាស់លាស់ និងមានលក្ខណៈងាយស្រួលក្នុងការយល់ និងមិនមានភាពសាំញ៉ាំហើយសមស្របទៅតាមបទដ្ឋាននៃការតាក់តែងសារណា ដែលសាកលវិទ្យាល័យបានកំណត់ ហេតុនេះស្នាដៃ

ស្រាវជ្រាវមួយនេះត្រូវបានរៀបចំចងក្រង ដោយធ្វើការបែងចែកជា ៣ជំពូក ហើយដែលក្នុងនោះរួមមាន ជំពូកទី ១៖ គោលការណ៍ទូទៅនៃអភិបាលកិច្ចល្អ ជំពូកទី ២៖ សកម្មភាពការងាររបស់ ក.ស.វ. និងជំពូកទី ៣៖ ការវិភាគលើការអនុវត្តការងារនៃ ក.ស.វ. ។

# ជំពូកទី ១
# គោលការណ៍ទូទៅនៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ គឺជាគោលការណ៍ថ្មីមួយ និងមានលក្ខណៈល្អប្រសើរសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈគ្រប់ទីកន្លែងទាំងអស់នៅទូទាំងសកលលោក។ រាជរដ្ឋាភិបាលកម្ពុជា ក៏បាន នឹងកំពុងប្រើប្រាស់នូវ គោលការណ៍នៃអភិបាលកិច្ចល្អនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធនៃរដ្ឋបាលសាធារណៈរបស់កម្ពុជាផងដែរ។

## ១.១. និយមន័យ

អភិបាលកិច្ចល្អ ត្រូវបានផ្ដល់និយមន័យផ្សេងៗជាច្រើនប្លែកៗពីគ្នាទៅតាមការកំណត់របស់ស្ថាប័ន ឬអង្គការជាតិនីមួយៗ។

នៅក្នុង វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត លោកបានផ្ដល់នូវនិយមន័យដល់ពាក្យ អភិបាល បានដល់ន័យដូច្នេះថាជា "ការគ្រប់គ្រង ការបីបាច់ ការថែរក្សា"[4]។ ក្នុងន័យនេះ ពាក្យថា អភិបាលកិច្ចល្អ បានន័យជារួមថា គឺជាកិច្ចការក្នុងការគ្រប់គ្រង បីបាច់ ថែរក្សា ពីសំណាក់រដ្ឋអំណាចទៅកាន់ប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យមានលក្ខណៈល្អប្រសើរ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋក៏ដូចជានៅក្នុងការទទួលសេវានានាពីរដ្ឋជាដើម។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភាក៏បានផ្ដល់និយមន័យដល់អភិបាលកិច្ច-ល្អថាគឺជា "បុរេលក្ខខណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព[5] សមធម៌ និងយុត្តិធម៌ក្នុងសង្គម" [6]។ តាមរយៈនិយមន័យដែលផ្ដល់ខាងលើនេះបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជា ពិតជាបានកំណត់ទុកថាអភិបាលកិច្ចល្អ ជាគន្លឹះមួយយ៉ាងចាំបាច់ ក្នុងការធ្វើឱ្យមានភាពប្រសើរឡើង នូវការអភិវឌ្ឍសង្គមដែលនាំមកនូវសុខដុមភាពរបស់ប្រជាជន តាមរយៈកំណើនសេដ្ឋកិច្ចជាប្រចាំ សម្រាប់ប្រជាជនគ្រប់ៗរូបដោយឥតប្រកាន់និន្នាការ និងប្រកាន់បាននូវយុត្តិធម៌ក្នុងសង្គម តាមរយៈកំណែទម្រង់រយៈពេលវែងដែលបាននឹងកំពុងធ្វើហើយនឹងនៅតែបន្តធ្វើនាពេលបច្ចុប្បន្ននេះ។

---

[4] ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ បណ្ណាគារពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ១៦៦៥។

[5] ចីរភាព (ន.) ភាពយឺតយូរ, ភាពយូរអង្វែង។

[6] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣* (ភ្នំពេញ, ២០១៣), ៣៩។

ក្រសួងមហាផ្ទៃ ក៏បានកំណត់នូវនិយមន័យរបស់ អភិបាលកិច្ចល្អផងដែរថា "ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ" [7]។

ស្ថាប័នទាំងនេះ កំពុងធ្វើការជាមួយគ្នាយ៉ាងសកម្មក្នុងគោលដៅ ដើម្បីឱ្យមានអភិបាលកិច្ច-ល្អនៅក្នុងសង្គម។ ក្រៅពីស្ថាប័នជាតិទាំងពីរខាងលើ ក្នុងនោះក៏មាននូវអង្គការ និងស្ថាប័នមួយចំនួនទៀតដែលបានផ្តល់ជានិយមន័យផ្សេងៗពីគ្នាទៅលើអភិបាលកិច្ចល្អ។

ធនាគារពិភពលោក (World Bank) បានផ្តល់នូវនិយមន័យដល់អភិបាលកិច្ចល្អថា "គឺជាវិធីសាស្ត្រដែលអំណាចរបស់រដ្ឋត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចរបស់ប្រទេស និងធនធានរបស់សង្គមដើម្បីធ្វើឱ្យមានការអភិវឌ្ឍ" [8]។

អង្គការសហប្រជាជាតិនៃកម្មវិធីអភិវឌ្ឍន៍ (United Nations Development Program) ក៏បានផ្តល់នូវនិយមន័យថា "អភិបាលកិច្ច ត្រូវបានមើលឃើញថា ជារបៀបមួយនៃការប្រើប្រាស់ អំណាចសេដ្ឋកិច្ច នយោបាយ និងរដ្ឋបាលក្នុងការគ្រប់គ្រងនូវរាល់កិច្ចការរបស់ប្រទេសជាតិនៅគ្រប់ជាន់ថ្នាក់ទាំងអស់" [9]។

ក្រៅពីទស្សនៈនៃអង្គការស្ថាប័នជាតិ និងអន្តរជាតិខាងលើ បើយោងទៅតាមទស្សនៈទូទៅ អភិបាលកិច្ចល្អ គឺជាការប្រើប្រាស់នូវសិទ្ធិអំណាចសាធារណៈ (នយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល) ក្នុងការដឹកនាំ និងគ្រប់គ្រងការងាររបស់ប្រទេសជាតិឱ្យមានលក្ខណៈល្អប្រសើរ។

## ១.២. គោលការណ៍នៃអភិបាលកិច្ចល្អ

តាមរយៈនិយមន័យខាងលើនេះ បានបង្ហាញនូវការផ្តល់និយមន័យយ៉ាងច្រើនពាក់ព័ន្ធដល់ពាក្យថាអភិបាលកិច្ចល្អ ពីស្ថាប័នផ្សេងៗជាច្រើនទាំងរដ្ឋ និងអង្គការអន្តរជាតិនានាជាដើម។ នៅក្នុងការផ្តល់និយមន័យនេះផងដែរ គោលការណ៍នៃអភិបាលកិច្ចល្អ របស់និយមន័យនីមួយៗនៃស្ថាប័នទាំងនោះត្រូវបានភ្ជាប់មកជាមួយដោយមានភាពប្លែកៗពីគ្នា។

[7] ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ* (ភ្នំពេញ, ២០១០), ៣។

[8] IFAD, *Good Governance: An Overview* [អភិបាលកិច្ចល្អ៖ ទិដ្ឋភាពទូទៅ] (Rome, 1999), 1, www.ifad.org/gbdocs/eb/67/e/EB-99-67-INF-4.pdf (ថតចម្លងថ្ងៃទី ២៥ មេសា ២០១៥)។

[9] IFAD, *Good Governance: An Overview* [អភិបាលកិច្ចល្អ៖ ទិដ្ឋភាពទូទៅ] (Rome, 1999), 5, www.ifad.org/gbdocs/eb/67/e/EB-99-67-INF-4.pdf (ថតចម្លងថ្ងៃទី ២៥ មេសា ២០១៥)។

## ១.២.១. គោលការណ៍នៃអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលកម្ពុជា

នៅក្នុងការផ្តល់និយមន័យដល់ពាក្យថាអភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥នៃរដ្ឋសភា ក៏មានគោលការណ៍មួយចំនួនត្រូវបានភ្ជាប់មកជាមួយនឹងនិយមន័យនោះផងដែរ។

គោលការណ៍នៃអភិបាលកិច្ចល្អ ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣។ ស្នូលនៃយុទ្ធសាស្ត្រដែលបានដាក់ចេញ ហើយត្រូវបានអនុវត្ត និងផ្តោតការយកចិត្តទុកដាក់នោះរួមមាន៖ (ក.) ការប្រយុទ្ធនឹងប្រឆាំងអំពើពុករលួយ (ខ.) កំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ (គ.) កំណែទម្រង់រដ្ឋបាលសាធារណៈ (ឃ.) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។[10]

### ក. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺជាចំណុចចម្បងជាងគេដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់។ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅតែជារបៀបវារៈមួយដែលមានអាទិភាពបំផុតព្រមទាំងមានសារៈសំខាន់ជាងគេ នៅក្នុងបញ្ជីនៃរបៀបវារៈ ទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥នៃរដ្ឋសភា។ ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១០ ហើយច្បាប់នេះបានក្លាយទៅជាគតិយុត្តគន្លឹះមួយ ដែលចាំបាច់មិនអាចខ្វះបានក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបានបន្ត នឹងបន្តប្រើប្រាស់នូវវិធានការមុតស្រួចជាយុទ្ធសាស្ត្រជាក់ស្តែងដែលអាចដោះស្រាយបញ្ហាអំពើពុករលួយប្រកបដោយ ប្រសិទ្ធភាពតាមរយៈវិធានការនានា ដែលក្នុងនោះយុទ្ធសាស្ត្រទាំងអស់ដែល មានការប្រទាក់ក្រឡាគ្នាសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរួមមាន៖ ១. ការបង្ការទប់ស្កាត់ជាមុន ២. ការពង្រឹងគណនេយ្យភាព និងពង្រឹងសមត្ថភាពស្ថាប័ន ៣. ការគាំទ្រ និងការចូលរួមពីសាធារណៈជន ៤. ការចូលរួមពីវិស័យឯកជន និង ៥. ការពង្រឹងការអនុវត្តច្បាប់ ។

[10] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣* (ភ្នំពេញ, ២០១៣), ៣៤។

### ខ. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ជាចំណុចសំខាន់នៃអភិបាលកិច្ចល្អផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានកែលម្អប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយផ្តោតជាសំខាន់ ទៅលើការរៀបចំក្របខណ្ឌច្បាប់ឱ្យបានរឹងមាំ និងតាមរយៈការធ្វើទំនើបកម្មច្បាប់ ព្រមទាំងការដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការចាំបាច់នានាក្នុងគោលដៅពង្រឹងសមត្ថភាព ឯករាជ្យភាព និងអព្យាក្រឹតភាពនៃប្រព័ន្ធតុលាការដែលជាកត្តាសំខាន់នៅក្នុងដំណើរការពង្រឹងនីតិរដ្ឋ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានបន្តរៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ ក្នុងគោលដៅបង្កើនការយល់ដឹង និងការអនុវត្តឱ្យបានត្រឹមត្រូវ។ រាជរដ្ឋាភិបាលកម្ពុជា បានបន្តផ្តល់អាទិភាពបន្ថែមទៀតទៅលើ៖ ១. ការពង្រឹងសមត្ថភាពរបស់ចៅក្រម ២. ការកសាងនូវយន្តការផ្សេងៗ ដែលចូលរួមបម្រើឱ្យវិស័យយុត្តិធម៌ ៣. ការផ្តល់ជំនួយផ្នែកច្បាប់ និង ៤. ការបន្តជំរុញលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

### គ. កំណែទម្រង់រដ្ឋបាលសាធារណៈ

កំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានរាជរដ្ឋាភិបាល ផ្តោតជាសំខាន់ទៅលើការធានាចំពោះការផ្តល់នូវសេវាសាធារណៈនានាជូនប្រជាពលរដ្ឋដែលប្រកបដោយ គុណភាព តម្លាភាព និងប្រសិទ្ធភាព។ សេវាសាធារណៈដែលមានចែង នៅក្នុងគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវបានចងក្រងប្រមូលផ្តុំជា ៧ ប្រភេទធំៗ ទៅតាមវិស័យនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន រួមមាន៖ ១. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យរដ្ឋ។ ២. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់។ ៣. ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល។ ៤. ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្មសហគ្រាសធុនតូចនិងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។ ៥. ចង្កោមសេវាពាក់ព័ន្ធនឹងសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី។ ៦. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ និង ៧. ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់។

បន្ថែមពីនេះទៀតតាមរយៈការបង្កើតនូវយន្តការ "ច្រកចេញចូលតែមួយ" គឺវាបានកាត់បន្ថយនូវការិយាធិបតេយ្យកិច្ចការងារ ព្រមទាំងបង្កើតឡើងនូវយន្តការមួយ ដើម្បីធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគ្មានអំពើពុករលួយតាមរយៈការបង្កើតការិយាល័យប្រជាពលរដ្ឋ។

### ឃ. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ត្រូវបានរាជរដ្ឋាភិបាលធ្វើឡើងដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពនូវអធិបតេយ្យ និងបូរណភាពទឹកដី សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀតរាជរដ្ឋាភិបាលបន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ជាពិសេសដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទមានជាអាទិ៍ ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងបទល្មើសនានា។[11]

## ១.២.២. គោលការណ៍នៃអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ ជាក្រសួងមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងនូវដំណើរការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានដូចជា ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ឃុំ ជាដើម។ តាមរយៈការដាក់ចេញនូវ ទ្រឹស្តីអភិបាលកិច្ចល្អក្នុងការធ្វើឱ្យប្រសើរឡើង នូវដំណើរការនៃការគ្រប់គ្រងរបស់ខ្លួនក៏ដូចជា ធ្វើឱ្យការបម្រើសេវារបស់ខ្លួនមានប្រសិទ្ធភាពនោះ តាមរយៈទ្រឹស្តីអភិបាលកិច្ចល្អ នេះក្រសួងក៏បានដាក់ភ្ជាប់មកជាមួយនូវគោលការណ៍ចំនួន ៩ ដែលក្នុងនោះរួមមាន៖ (ក). ការចូលរួម (ខ.) នីតិរដ្ឋ (គ.) តម្លាភាព (ឃ.) ការព្រមព្រៀងឯកភាពគ្នា (ង.) សមធម៌ (ច.) ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (ឆ.) គណនេយ្យភាព (ជ.) ការឆ្លើយតប (ឈ.) ចក្ខុវិស័យជាយុទ្ធសាស្ត្រ។[12]

### ក. ការចូលរួម

ការចូលរួម ដែលត្រូវបានកំណត់ជាគោលការណ៍ក្នុងអភិបាលកិច្ចល្អ គឺសំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីដែលអាចជា អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗ នៅក្នុងដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ ការចូលរួមពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាការចូលរួម គឺធានាបាននូវព័ត៌មានស្តីពី

[11] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣* (ភ្នំពេញ, ២០១៣), ៣៥-៤៥។

[12] ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ* (ភ្នំពេញ, ២០១០), ៦។

បញ្ហាតម្រូវការ និងបំណងប្រាថ្នាទាំងឡាយរបស់ប្រជាពលរដ្ឋគ្រប់ៗរូបគឺត្រូវបានប្រមូល និងធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយមុនពេលដែលឈានទៅដល់ការសម្រេចចិត្ត ដើម្បីប្រាកដថាគ្រប់ភាគីទាំងអស់អាចទទួលបានប្រយោជន៍ព្រមទាំងទទួលយកបាននូវអ្វីដែលជាការសម្រេចចិត្តនោះ។

ការចូលរួម ត្រូវបានធ្វើឡើងដោយរបៀបពីរ គឺការចូលរួមដោយផ្ទាល់ និងមិនផ្ទាល់។ ការចូលរួមដោយផ្ទាល់ សំដៅដល់ការចូលរួមទាំងឡាយ ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវមកចូលរួមដោយខ្លួនឯង នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តនូវសេចក្តីសម្រេចចិត្តនោះ។ ជាក់ស្តែងដូចជាការចូលរួមប្រជុំ លើផែនការអភិវឌ្ឍមូលដ្ឋានភូមិឃុំ ដែលខ្លួនរស់នៅ ការបោះឆ្នោត និងការឈរឈ្មោះបោះឆ្នោតជាដើម។ ការចូលរួមមិនផ្ទាល់ សំដៅដល់ការចូលរួមទាំងឡាយ ដែលមានអ្នកតំណាងរបស់ប្រជាពលរដ្ឋមកធ្វើការចូលរួមនៅក្នុង ដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ អ្នកតំណាងប្រជាពលរដ្ឋចាំបាច់ត្រូវតែបម្រើឱ្យឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ។

### ខ. នីតិរដ្ឋ

នីតិរដ្ឋនៅក្នុងន័យនៃអភិបាលកិច្ចល្អ គឺជាការទាមទារឱ្យមាននូវឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ការពារសិទ្ធិមនុស្ស ជាពិសេសនោះគឺក្រុមទាំងឡាយដែលងាយរងគ្រោះ ឬក្រុមភាគតិចជាដើម ហើយដែលច្បាប់ទាំងអស់នោះត្រូវបានអនុវត្តដោយមិនមានភាពលំអៀង។ បន្ថែមពីនេះទៀតក្នុងដំណើរការងារ ក៏ត្រូវមានប្រព័ន្ធទទួលខុសត្រូវមួយ មានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀងព្រមទាំងគ្មានអំពើពុករលួយ។

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អនេះផងដែរ ត្រូវបានផ្តោតជាចម្បងទៅលើ ១. ឯកសារក្របខណ្ឌច្បាប់ ២. ការការពារសិទ្ធិមនុស្ស ៣. ប្រព័ន្ធទទួលខុសត្រូវ ៤. ប្រព័ន្ធយុត្តិធម៌ ៥. សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

### គ. តម្លាភាព

តម្លាភាពត្រូវបានផ្តល់ន័យនៅក្នុងអភិបាលកិច្ចល្អថា គឺជាការសម្រេចចិត្តទាំងឡាយណា និងការអនុវត្តនូវរាល់សេចក្តីសម្រេចទាំងឡាយណាដែលត្រូវធ្វើឡើង៖ ១. ដោយមានការអនុលោមទៅតាមច្បាប់និងបទដ្ឋាននានា។ ២. ព្រមទាំងមានការផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធផ្សព្វផ្សាយសមស្របដែលអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេច

និងការអនុវត្តនូវការសម្រេចចិត្តទាំងនោះ។ ៣. ហើយដែលព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់អាចទទួលយកបាន និងមិនពិបាកយល់។

### ឃ. ការព្រមព្រៀងឯកភាពគ្នា

ការព្រមព្រៀងឯកភាពគ្នា នៅក្នុងន័យរបស់អភិបាលកិច្ចល្អ គឺជាការពិចារណាបែបទូលំទូលាយ វែងឆ្ងាយលើប្រយោជន៍ និងតម្រូវការនានារបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្ត ដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍សាធារណៈ។

ដើម្បីឱ្យមាន ការព្រមព្រៀងឯកភាពគ្នាក្នុងដំណើរការងារ លក្ខខណ្ឌមួយចំនួនត្រូវបានណែនាំដូចជា៖ ១. ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា។ ២. ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់។ ៣. ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ ៤. ការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងក្រុមពាក់ព័ន្ធទាំងអស់ ។

### ង. សមធម៌

សមធម៌ ក៏ត្រូវបានផ្តល់អត្ថន័យនៅក្នុងអភិបាលកិច្ចល្អថា រាល់ក្រុម ឬជនគ្រប់រូបទាំងអស់ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ ត្រូវតែមានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញមតិយោបល់ លើកឡើងនូវតម្រូវការពិតពាក់ព័ន្ធទៅនឹង ការអនុវត្តសកម្មភាពការងារនិងទទួលផលប្រយោជន៍សមស្របដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ បន្ថែមពីនេះទៀតពួកគេមានអារម្មណ៍ថា ពួកគេគឺជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ។ សុខុមាលភាពរបស់ សមាជិក ឬក្រុមនីមួយៗគឺជាសុខុមាលភាពរបស់សង្គមទាំងមូល។ ដូចនេះដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តប្រកបដោយសមធម៌នឹងធ្វើឱ្យ គ្រប់សមាជិកទាំងអស់ក្នុងសង្គម មានអារម្មណ៍ថាពួកគេម្នាក់ៗគឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកនៅក្នុងដំណើរការអភិវឌ្ឍសង្គមនោះ។

### ច. ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ

ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ក្នុងន័យអភិបាលកិច្ចល្អមានន័យថាជាដំណើរការ និងរចនា-សម្ព័ន្ធគ្រប់គ្រងទាំងឡាយណា ដែលប្រើប្រាស់រាល់ធនធានទាំងឡាយ ឱ្យអស់លទ្ធភាព និងមានការសន្សំសំចៃខ្ពស់ ដើម្បីធ្វើការបង្កើតលទ្ធផល ដែលមានគុណភាពខ្ពស់ បរិមាណច្រើនដែលអាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅនឹងតម្រូវការពិតរបស់សង្គម។ គោលគំនិត

នៃភាពស័ក្តិសិទ្ធិនៅក្នុងបរិបទនៃអភិបាលកិច្ចល្អ ក៏រាប់បញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថានឱ្យបានល្អប្រសើរ។

ក្នុងការធ្វើឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តការងារ ការពិចារណាទៅលើចំណុចមួយចំនួនពិតជាមានការចាំបាច់ដូចជា៖ ១. ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវដោយរាប់បញ្ចូលទាំងធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈ និងពេលវេលា។ ២. ការអនុវត្តសកម្មភាពដែលជាសកម្មភាពអាទិភាពខ្ពស់។ ៣. ជៀសវាងការអនុវត្តនូវការិយាធិបតេយ្យ។ ៤. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ។ ៥. គ្មានអំពើពុករលួយក្នុងសកម្មភាពការងារជាដើម។

### ឆ. គណនេយ្យភាព

គណនេយ្យភាព នៅក្នុងអភិបាលកិច្ចល្អមានន័យថា គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្ដីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយធ្វើការរាយការណ៍ហើយមានការបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។

គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវ ចំពោះមុខនរណាម្នាក់ ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។ មិនមែនមានតែស្ថាប័ន និងអង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេដែលត្រូវមានគណនេយ្យភាព ប៉ុន្តែអង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជននានា ក៏ត្រូវមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធរបស់ខ្លួនផងដែរជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់អំពីការសម្រេចចិត្ត។ គណនេយ្យភាព រួមមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និងចំពោះមុខសាធាណៈជន។

### ជ. ការឆ្លើយតប

ការឆ្លើយតប ក្នុងន័យនៃអភិបាលកិច្ចល្អមានន័យថា ជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័នដើម្បីបម្រើប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នាព្រមទាំងគ្មានការរើសអើងនៅក្នុងក្របខណ្ឌពេលវេលាមួយដ៏សមហេតុផលផងដែរ។

ការឆ្លើយតបក្នុងន័យនេះអាចជា៖ ១. ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ។ ២. ដំណោះស្រាយដែលស្តែងឡើង ជាសកម្មភាពដើម្បីសោះស្រាយបញ្ហា ឬការលំបាកនានារបស់ពលរដ្ឋ។ ៣.ការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានាទាំងនោះបាន។ ៤. សំណើសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ច

ដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំងនោះព្រមទាំងប្រាប់អំពីសំណើសុំអន្តរាគមន៍នោះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬការលំបាកទាំងនោះ។

### ឈ. ចក្ខុវិស័យជាយុទ្ធសាស្ត្រ

ចក្ខុវិស័យជាយុទ្ធសាស្ត្រ ជាប្រការចាំបាច់ណាស់សម្រាប់អ្នកដឹកនាំ នៅក្នុងគោលការណ៍នៃអភិបាលកិច្ចល្អ។ អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្ស ដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានាដែលត្រូវអភិវឌ្ឍន៍លើការងារនោះ។ ជាងនេះទៅទៀតអ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឱ្យបានច្បាស់អំពីទិដ្ឋភាពទាំងឡាយ ដែលពាក់ព័ន្ធដល់ផ្នែកប្រវត្តិសាស្ត្រព្រមទាំងវប្បធម៌ និងសង្គមដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ចល្អ។[13]

## ១.២.៣. គោលការណ៍នៃអភិបាលកិច្ចល្អរបស់ធនាគារពិភពលោក

ធនាគារពិភពលោក ជាធនាគារលំដាប់អន្តរជាតិមួយ ដែលធ្វើការងារយ៉ាងសំខាន់នៅក្នុងការផ្តល់នូវប្រភពនៃហិរញ្ញវត្ថុ ជាមួយនឹងការប្រឹក្សាផ្នែកបច្ចេកទេស សម្រាប់ការអភិវឌ្ឍប្រទេសនានានៅទូទាំងពិភពលោក។ ដោយមើលឃើញពីគុណសម្បត្តិនៃអភិបាលកិច្ចល្អ ក្នុងការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការអភិវឌ្ឍ គោលការណ៍មួយចំនួនក៏ត្រូវបានកំណត់ឡើងក្នុងការធ្វើឱ្យទ្រឹស្តីអភិបាលកិច្ចល្អ មានភាពច្បាស់លាស់ សម្រាប់ការប្រើប្រាស់។ គោលការណ៍នានានៃអភិបាលកិច្ចល្អដែលត្រូវបានដាក់ចេញនោះរួមមាន ៤ ចំណុចសំខាន់ដូចជា៖ (ក.) ការគ្រប់គ្រងវិស័យសាធារណៈ (ខ.) គណនេយ្យភាព (គ.) ក្របខណ្ឌច្បាប់សម្រាប់ការអភិវឌ្ឍ (ឃ.) តម្លាភាព និងព័ត៌មាន។[14]

### ក. ការគ្រប់គ្រងវិស័យសាធារណៈ

ការគ្រប់គ្រងវិស័យសាធារណៈ គឺជាខ្នាតសម្រាប់វាស់វែងមួយ ដែលមានលក្ខណៈពេញលេញសម្រាប់ធ្វើការវាស់វែង នូវដំណើរការការងារនៃអភិបាលកិច្ចល្អ របស់ធនាគារពិភពលោក។ ការគ្រប់គ្រងវិស័យសាធារណៈ គឺមានន័យសំដៅទៅដល់ ការធ្វើកំណែទម្រង់នូវរចនាសម្ព័ន្ធនៃស្ថាប័នសាធារណៈដើម្បីធ្វើឱ្យសម្រេចបាន នូវគោលគំនិតនានា រួមទាំងធ្វើឱ្យការគ្រប់គ្រងនូវថវិកា

[13] ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ* (ភ្នំពេញ, ២០១០), ៦-១៨។

[14] IFAD, *Good Governance: An Overview* [អភិបាលកិច្ចល្អ៖ ទិដ្ឋភាពទូទៅ] (Rome, 1999), 2, www.ifad.org/gbdocs/eb/67/e/EB-99-67-INF-4.pdf (ថតចម្លងថ្ងៃទី ២៥ មេសា ២០១៥)។

នៃស្ថាប័នមានលក្ខណៈល្អប្រសើរ។ ក្នុងនោះផងដែរការធ្វើឱ្យប្រសើរឡើងនូវមុខងារសាធារណៈរបស់រដ្ឋ និងការគ្រប់គ្រងឱ្យម៉ត់ចត់នូវសហគ្រាសសាធារណៈនានា ក៏ជាផ្នែកមួយនៃការគ្រប់គ្រងវិស័យសាធារណៈផងដែរ។

**ខ. គណនេយ្យភាព**

គណនេយ្យភាព នៅក្នុងការប្រព្រឹត្តទៅនៃការងារពិតជាមានសារៈសំខាន់ ជាពិសេសដំណើរការការងាររបស់វិស័យសាធារណៈ។ ដូចនេះនៅក្នុងដំណើរការងារ នៃវិស័យសាធារណៈទាំងរដ្ឋ និងមន្ត្រីទាំងអស់របស់រដ្ឋ ត្រូវតែមានទំនួលខុសត្រូវលើសកម្មភាពរបស់ខ្លួនដោយរាប់បញ្ចូលទាំងការសម្រេចចិត្ត និងការអនុវត្តការសម្រេចចិត្តនានាផងដែរ។

**គ. ក្របខណ្ឌច្បាប់សម្រាប់ការអភិវឌ្ឍ**

ប្រព័ន្ធច្បាប់ជាក់លាក់មួយ គួរតែត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ច្បាប់ទាំងនោះទៅតាមវិស័យឱ្យបានច្បាស់លាស់ ហើយច្បាប់ទាំងនោះគួរតែផ្តល់នូវស្ថិរភាព និងការអនុវត្តបានយូរអង្វែង។ ប្រព័ន្ធច្បាប់ទាំងនោះគឺចាំបាច់ណាស់សម្រាប់ការបង្កើតនូវបរិយាកាសវិនិយោគមួយ ដែលអំណោយផលដល់ការវិនិយោគ ព្រោះថានៅពេលដែលបរិយាកាសក្នុងការវិនិយោគ មានលក្ខណៈល្អប្រសើរ ពេលនោះបញ្ហាប្រឈមនៃការធ្វើជំនួញអាចនឹងត្រូវបានកាត់បន្ថយ ហើយនឹងនាំទៅរកកំណើននៃការវិនិយោគសម្រាប់ការអភិវឌ្ឍ។

**ឃ. តម្លាភាព និងព័ត៌មាន**

តម្លាភាព គឺជាភាពថ្លាឆ្លុះមិនមានការលាក់បាំង។ ឯព័ត៌មានដែលអាចស្វែងរកបានពីប្រភពផ្សេងៗពីគ្នាគឺបង្ហាញពីភាពទូលាយនៃការមើលឃើញ និងអាចតាមដានបាននូវអ្វីដែលសង្គមចង់ដឹង និងចង់តាមដាន។ តម្លាភាព និងព័ត៌មាន ជាកត្តាមួយយ៉ាងសំខាន់ដែលជំរុញឱ្យមានអភិបាល-កិច្ចល្អរួមផ្សំ និងការបង្កើតឱ្យមានគណនេយ្យភាពក្នុងការអនុវត្តការងារផងដែរ។ [15]

[15] IFAD, *Good Governance: An Overview* [អភិបាលកិច្ចល្អ៖ ទិដ្ឋភាពទូទៅ] (Rome, 1999), 2, www.ifad.org/gbdocs/eb/67/e/EB-99-67-INF-4.pdf (ថតចម្លងថ្ងៃទី ២៥ មេសា ២០១៥)។

# ជំពូកទី ២

# សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ២.១. ប្រវត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ដំបូងឡើយនៅក្នុងឆ្នាំ១៩៩៩ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលហៅកាត់ថា ក.ស.ស.ស.[16] ។ នៅក្នុងក្រុមប្រឹក្សាសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នេះគឺមានសមាសភាពចំនួន ១៦រូបដែលក្នុងនោះរួមមានឯកឧត្តម សុន គន្ធរ ជាប្រធានមានឋានៈស្មើរដ្ឋមន្ត្រី និងឯកឧត្តម យិន គិនស៊ាន ជាអនុប្រធានមានឋានៈស្មើ អនុរដ្ឋលេខាធិការ និងតែងតាំងដោយព្រះរាជក្រឹត្យ។[17] ក.ស.ស.ស. មានតួនាទី និងភារកិច្ចដូចជា៖ សិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានដើម្បីធ្វើការវិភាគវាយតម្លៃទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅក្នុងប្រទេស ព្រមទាំងធ្វើការវិភាគវាយតម្លៃលើស្ថានភាពសេដ្ឋកិច្ច ស្ថានភាពការងារ និងធុរៈកិច្ច សកម្មភាពផលិតកម្មស្របតាមសេដ្ឋកិច្ចក្រៅប្រទេស និងតុល្យភាពថវិកា។ មួយវិញទៀតដើម្បីធ្វើការវាយតម្លៃលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សម្ភារៈប្រើប្រាស់ ស្មារតីសង្គមកិច្ចសុខាភិបាល និងវប្បធម៌ ព្រមទាំងធ្វើការផ្តល់យោបល់ និងរិះរកដំណោះស្រាយបញ្ហាផ្សេងៗ ដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ក.ស.ស.ស. ក៏មានតួនាទីភារកិច្ចផ្សេងទៀតផងដែរក្នុងការសហការ និងផ្តល់សេវាជាអចិន្ត្រៃយ៍ ឱ្យដល់ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដែលនឹងត្រូវបង្កើត និងសហការយ៉ាងជិតស្និទ្ធក្នុងការផ្លាស់ប្តូរព័ត៌មាន និងបច្ចេកទេសជាមួយស្ថាប័នជាតិ ឬអង្គការអន្តរជាតិផ្សេងៗលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ នៅក្នុងអគ្គលេខាធិការដ្ឋាននៃ ក.ស.ស.ស. ត្រូវបានដឹកនាំដោយ អគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងបីរូបជាជំនួយការដែលអគ្គលេខាធិការរងមានឋានៈស្មើអគ្គនាយក។ បន្ទាប់មកនៅឆ្នាំ២០០៩ ក.ស.ស.ស. ត្រូវបានប្តូរពីក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មកជាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលហៅកាត់ថា ក.ស.វ. រហូតមកដល់ពេលបច្ចុប្បន្ននេះ។

---

[16] អនុក្រឹត្យស្តីពី ការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ០៥អនក្រ/តត, ១១ មករា ១៩៩៩, មាត្រា១។

[17] អនុក្រឹត្យស្តីពី ការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ០៥អនក្រ/តត, ១១ មករា ១៩៩៩, មាត្រា២។

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានសមាសភាពដូចតទៅះ

១. ឥស្សរជនជាន់ខ្ពស់មួយរូប ជាប្រធាន

២. ឥស្សរជនមួយចំនួន ជាអនុប្រធាន

៣. ឥស្សរជន ឬអ្នកជំនាញមួយចំនួន ជាសមាជិក

៤. អ្នកបច្ចេកទេសមួយចំនួនតាមតម្រូវការចាំបាច់ ជាសមាជិកបម្រុង

ប្រធាន អនុប្រធាន សមាជិក(អចិន្ត្រៃយ៍ និងមិនអចិន្ត្រៃយ៍) និងសមាជិកបម្រុងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ ក.ស.វ. អាចមានអ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញ និងមានបទពិសោធខ្ពស់សម្រាប់ជួយការងារជាទីប្រឹក្សាបច្ចេកទេស។ ក.ស.វ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់កិច្ចដំណើរការការងារប្រចាំថ្ងៃ។

## ២.២. សមត្ថកិច្ច និងភារកិច្ចរបស់ ក.ស.វ.

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មានមុខងារ និងភារកិច្ចដូចខាងក្រោមះ

ធ្វើការពិនិត្យតាមដាននូវស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលមានការប្រែប្រួលទៅតាមស្ថានភាពប្រចាំខែ និងប្រចាំឆ្នាំដោយធ្វើការប្រមូលទិន្នន័យទាំងនេះពីបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធដើម្បីផ្ញើជូនដល់រាជរដ្ឋាភិបាល។ ធ្វើការវិភាគ ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាប្រឈមដែលជះឥទ្ធិពលលើ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលបង្កជាផលវិបាកដល់ការអភិវឌ្ឍប្រទេសជាតិ ក៏ដូចជាស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនោះផងដែរ ក.ស.វ. ក៏បានធ្វើការត្រួតពិនិត្យ និងស្រាវជ្រាវទៅតាមភារកិច្ច ដែលគណៈរដ្ឋមន្ត្រីក៏ដូចជារាជរដ្ឋាភិបាលប្រគល់ជូន ព្រមទាំងរិះរកគ្រប់មធ្យោបាយ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងសម្រាប់ឆ្លើយតបទៅនឹងស្ថានភាពវិវត្ត និងបញ្ហាប្រឈមក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ការប្រមើលមើលនូវស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលអាចនឹងកើតឡើងនាពេលអនាគតក៏ត្រូវបានធ្វើឡើង ហើយបន្ទាប់មកផ្តល់ជាមតិយោបល់ ជូនរាជរដ្ឋាភិបាល។ មិនត្រឹមតែប៉ុណ្ណោះការពិនិត្យ និងផ្តល់មតិយោបល់ លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តគោលនយោបាយ កិច្ចព្រមព្រៀង និងឯកសារផ្សេងៗទៀតដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលក៏ជាតួនាទីរបស់ ក.ស.វ. ផងដែរ។ លើសពីនេះទៀត ក.ស.វ. ក៏បានធ្វើការប្រមូលចងក្រងទិន្នន័យ និងព័ត៌មានដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងបង្កើតនូវកិច្ចសហប្រតិបត្តិ

ការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័ននានា ដែលមានការពាក់ព័ន្ធដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មាននានា ។[18]

ក.ស.វ. បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាននៃ ក.ស.វ. ឬតាមសេចក្តីបង្គាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី ឬក៏តាមបង្គាប់របស់រាជរដ្ឋាភិបាល។ មិនត្រឹមតែប៉ុណ្ណោះ ក.ស.វ. ក៏មានសិទ្ធិផងដែរនៅក្នុងការកោះអញ្ជើញ នូវថ្នាក់ដឹកនាំជំនាញតំណាងក្រសួងស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ឱ្យចូលរួមប្រជុំដើម្បីជួយបំភ្លឺ និងធ្វើការផ្តល់ព័ត៌មានពិស្តារពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ នៅពេលដែលមានការកោះអញ្ជើញហើយ ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវធ្វើការផ្តល់ជាព័ត៌មានព្រមទាំងទិន្នន័យ និងផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធិជូន ក.ស.វ. ដើម្បីឱ្យការបំពេញការងារប្រកបដោយ ប្រសិទ្ធភាពខ្ពស់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក៏ដូចជារាជរដ្ឋាភិបាល។ មួយវិញទៀត នៅពេលដែលមានកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងកិច្ចប្រជុំអន្តរក្រសួងនានា ក.ស.វ. ត្រូវមានតំណាងដើម្បីធ្វើការចូលរួមក្នុងសម័យប្រជុំទាំងនោះ។

## ២.៣. មុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ ក.ស.វ.

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មានអគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការសម្រាប់កិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ ក.ស.វ. និងត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ។ មន្ត្រីបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃទីស្តីការគណៈរដ្ឋ-មន្ត្រី។ អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ត្រូវបានកំណត់នូវតួនាទី និងភារកិច្ចដូចជា៖ បំពេញការងារខាងផ្នែករដ្ឋបាល ផ្គត់ផ្គង់ និងបច្ចេកទេស ក្នុងកិច្ចដំណើរការរបស់ ក.ស.វ. ប្រកបដោយប្រសិទ្ធភាព។ នៅពេលដែលមានកិច្ចប្រជុំនានានៅក្នុង ក.ស.វ. អគ្គលេខាធិការដ្ឋានជាអ្នករៀបចំនូវកិច្ចប្រជុំខ្លួនឯងដោយផ្ទាល់ ឬសហការជាមួយអគ្គលេខាធិការរាជរដ្ឋាភិបាល។ អគ្គលេខាធិការដ្ឋាន ក.ស.វ. ក៏រៀបចំផងដែរនូវផែនការ និងវគ្គបណ្តុះបណ្តាលនានាដើម្បីពង្រឹង និងបង្កើនសមត្ថភាពមន្ត្រីនៃអគ្គលេខាធិការដ្ឋាន។ ធ្វើការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.វ. ដាក់ជូន ក.ស.វ. ដើម្បីពិនិត្យ និងសម្រេច។ ប្រមូលយកនូវឯកសារ ឬទិន្នន័យព័ត៌មានពីបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្រាប់ ក.ស.វ. ធ្វើការវិភាគ និងពិនិត្យតាមដានទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ និងប្រចាំឆ្នាំ។ អគ្គលេខាធិការ-ដ្ឋាននេះផងដែរក៏ជួយសម្រួលដល់ ក.ស.វ. ក្នុងការវិភាគលើបញ្ហាប្រឈមសំខាន់ៗដែលអាចមាន

[18] ព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ នស/រកត/០២០៩/១៧៣, ១៧ កុម្ភៈ ២០០៩, មាត្រា២។

ការជះឥទ្ធិពលលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ក៏បង្កើតឱ្យមានជាក្រុមការងារដើម្បីធ្វើការសិក្សាលើប្រធានបទដែល ក.ស.វ. បានរៀបចំឱ្យប្រតិបត្តិដោយកំណត់កាលបរិច្ឆេទ និងរយៈពេលជាក់លាក់។នៅពេលដែល ក.ស.វ. ធ្វើការព្យាករណ៍នូវស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អគ្គលេខាធិការដ្ឋានជាអ្នកជួយការងារបច្ចេកទេស ព្រមទាំងរៀបចំឯកសារយោង និងលិខិតពាក់ព័ន្ធសម្រាប់កិច្ចប្រជុំរបស់ ក.ស.វ. ក្នុងកិច្ចដំណើរការពិនិត្យផ្តល់យោបល់ លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី។ អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ធ្វើការរក្សាទុកនូវរាល់ឯកសារ ប្រព័ន្ធទិន្នន័យ និងព័ត៌មាន ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាដែលមានការទាក់ទងនឹងតម្រូវការរបស់ ក.ស.វ.។ មួយវិញទៀតអគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ក៏បានបង្កើតឱ្យមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួងស្ថាប័នជាតិ និងអន្តរជាតិនានាឱ្យកាន់តែមានប្រសិទ្ធភាព និងធ្វើនូវកិច្ចការផ្សេងៗដែលប្រធាន ក.ស.វ. បានដាក់ឱ្យ។[19]

## ២.៤. មុខងារ និងភារកិច្ចរបស់ផ្នែកនីមួយៗនៃអគ្គលេខាធិការដ្ឋាន ក.ស.វ.

នៅក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានចែងដោយអនុក្រឹត្យនេះ ត្រូវបានបែងចែកជាផ្នែកតូចៗជាច្រើន ដែលបានកំណត់នូវតួនាទីរបស់ផ្នែកនីមួយៗផ្សេងៗពីគ្នាដើម្បីឱ្យដំណើរការការងារប្រព្រឹត្តទៅបានល្អ។

អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. មានរចនាសម្ព័ន្ធដូចតទៅៈ

-ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ

-ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

-ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេត

-ផ្នែកលិខិតបទដ្ឋានគតិយុត្ត

-ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន

-ផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ។ [20]

[19] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា២។

[20] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា៤។

### ២.៤.១. ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ

ផ្នែករដ្ឋបាលនេះមានតួនាទីយ៉ាងសំខាន់ ក្នុងការបំពេញការងារនៅក្នុង ក.ស.វ. ព្រោះផ្នែករដ្ឋបាលធ្វើការគ្រប់គ្រងទៅលើគ្រប់បុគ្គលិកទាំងអស់ និងរដ្ឋបាលទាំងមូលដើម្បីឱ្យ ក.ស.វ. បំពេញភារកិច្ចជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលបានល្អ។ ផ្នែករដ្ឋបាលនេះមានតួនាទី និងភារកិច្ចដូចតទៅ៖ បំពេញការងាររដ្ឋបាល ក្នុងការងារប្រចាំថ្ងៃរបស់ ក.ស.វ. ព្រមទាំងរៀបចំផែនការគ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការទាំងអស់នៃអគ្គលេខាធិការដ្ឋាន ក.ស.វ. និងផែនការក្នុងការបណ្តុះបណ្តាលនានាសម្រាប់ពង្រឹង និងបង្កើនសមត្ថភាពបុគ្គលិក ដែលបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព និងទទួលបាននូវប្រសិទ្ធផលខ្ពស់។ មួយវិញទៀតផ្នែករដ្ឋបាល ក៏ត្រូវធ្វើការរៀបចំនូវកិច្ចប្រជុំនានាដែលបានរៀបចំឡើងដោយ ក.ស.វ. ព្រមទាំងសកម្មភាពការងារផ្សេងទៀតដែល ក.ស.វ. បានដាក់ចេញ។ តួនាទីមួយទៀតគឺធ្វើការរៀបចំព្រឹត្តិបត្រប្រចាំខែ និងព្រឹត្តិបត្រដទៃទៀតរបស់ ក.ស.វ. ព្រមទាំងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ ក.ស.វ. ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ។ ផ្នែករដ្ឋបាលបុគ្គលិក និងពិធីការនេះក៏ទទួលបន្ទុកការងារផ្សេងៗមួយចំនួនទៀតផងដែរ ដែលអគ្គលេខាធិការដ្ឋាន ក.ស.វ. បានប្រគល់ឱ្យ។ [21]

### ២.៤.២. ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់

នៅក្នុងអគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ក៏មានផ្នែកមួយដែលមានតួនាទីក្នុងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដើម្បីឱ្យ ក.ស.វ. ដំណើរការបានរលូន។ ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់មានតួនាទី និងភារកិច្ចដូចតទៅ៖ ផ្នែកហិរញ្ញវត្ថុមានតួនាទីក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.វ. និងការគ្រប់គ្រងការផ្គត់ផ្គង់ជូន ក.ស.វ. ដើម្បីធ្វើឱ្យ ក.ស.វ. ដំណើរការបានល្អគ្រប់ផ្នែក ព្រមទាំងធ្វើការរៀបចំផងដែរនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ ក.ស.វ.។ ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ក៏ធ្វើការស្វែងរកនូវលទ្ធភាព ក្នុងការទទួលបាននូវប្រភពថវិកាពី រដ្ឋ ជំនួយ អំណោយនានា ដើម្បីបង្កើនថវិកាប្រចាំឆ្នាំរបស់ ក.ស.វ.។ ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ធ្វើការ

[21] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៨អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា៨។

គ្រប់គ្រងចលនទ្រព្យរបស់ ក.ស.វ. ដោយការពារនូវទ្រព្យសម្បត្តិ ឬចលនទ្រព្យទាំងអស់ឱ្យបាន គង់វង្ស និងបំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ក.ស.វ.។ [22]

### ២.៤.៣. ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ការព្យាករណ៍ជាផ្នែកមួយដ៏សំខាន់នៃការងាររបស់ ក.ស.វ. ដើម្បីឱ្យដឹងពីស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ថាមានការរីកចម្រើន កើនឡើង ឬថយចុះពីមួយខែទៅមួយខែ និង ពីមួយឆ្នាំទៅមួយឆ្នាំ។ ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នេះមាន តួនាទីដូចតទៅ៖ ប្រមូលទិន្នន័យ និងព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ពីបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធនានា សម្រាប់ប្រចាំខែ និងប្រចាំឆ្នាំ។ ការប្រមូលទិន្នន័យនេះគឺសម្រាប់ ក.ស.វ. ធ្វើ ការវាយតម្លៃពីស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំងធ្វើការវិភាគអំពីមូលហេតុនៃការ កើនឡើង ឬថយចុះនៃកំណើនសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ ប្រចាំឆ្នាំ ហើយធ្វើការបូក សរុបទិន្នន័យបន្ទាប់ពីធ្វើការវិភាគ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។ ធ្វើការរៀបចំតារាង ទិន្នន័យនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលមានការវិវត្តប្រចាំខែ និងប្រចាំឆ្នាំព្រម ទាំងធ្វើការចងក្រងសៀវភៅស្ដីពី ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ និង ប្រចាំឆ្នាំផងដែរ ។ មិនតែប៉ុណ្ណោះផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏ ដើរតួធ្វើជាជំនួយការបច្ចេកទេសជូន ក.ស.វ. ដើម្បីជួយធ្វើការព្យាករណ៍បញ្ហាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលអាចនឹងកើតឡើងនាពេលអនាគត។ ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏ធ្វើការបំពេញការងារផ្សេងៗទៀតផងដែរ ទៅតាមរយៈការប្រគល់ជូនពី អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ។ [23]

### ២.៤.៤. ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេត

ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេតមានតួនាទីដូចតទៅ៖ ធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ដែលជាបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌តាមការ កំណត់របស់ ក.ស.វ.។ ការសិក្សាលើបញ្ហាប្រឈមទាំងនេះគឺសិក្សាទៅលើផលអវិជ្ជមានមួយចំនួន ដែលមានផលប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ហើយដែលជាឧបសគ្គរាំង

[22] អនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា៩។

[23] អនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា១០។

ដល់ការអភិវឌ្ឍប្រទេសជាតិ។ ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេតធ្វើការអង្កេតលើប្រធានបទពិសេស ដែល ក.ស.វ. បានកំណត់ឱ្យតាមកាលបរិច្ឆេទ និងរយៈពេលច្បាស់លាស់ដោយត្រូវ៖

-រៀបចំផែនការការងារ កម្រងសំណួរចម្លើយ និងវិធីសាស្ត្រសម្រាប់ធ្វើការអង្កេត

-ប្រមូល និងបញ្ចូលទិន្នន័យអង្កេតក្នុងប្រព័ន្ធវិភាគ

-ធ្វើការវិភាគលើទិន្នន័យ និងព័ត៌មានដែលបានមកពីការអង្កេត

ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេតក៏រៀបចំរបាយការណ៍លទ្ធផលនៃការសិក្សា ស្រាវជ្រាវ និងអង្កេតដាក់ជូន ក.ស.វ. សម្រាប់ពិនិត្យ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល។ ការរៀបចំរបាយការណ៍នេះធ្វើឡើងបន្ទាប់ពីផ្នែកសិក្សាស្រាវជ្រាវ និងអង្កេតធ្វើការប្រមូលនូវគ្រប់ទិន្នន័យពីបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងអស់។ លើសពីនេះទៅទៀតផ្នែកសិក្សាស្រាវជ្រាវ និងអង្កេតក៏បំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ក.ស.វ. ផងដែរ។ [24]

### ២.៤.៥. ផ្នែកលិខិតបទដ្ឋានគតិយុត្ត

ផ្នែកលិខិតបទដ្ឋានគតិយុត្តមានតួនាទី និងភារកិច្ចដូចជា៖ រៀបចំឯកសារយោង និងពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំរបស់ ក.ស.វ. ក្នុងដំណើរការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារលិខិតបទដ្ឋាន ដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី។ នៅពេលដែលមានកិច្ចប្រជុំនានាទាក់ទងនឹងការធ្វើសេចក្តីព្រាងនោះ ផ្នែកលិខិតបទដ្ឋានគតិយុត្តធ្វើការរៀបចំនូវរាល់ឯកសារនានាសម្រាប់អង្គប្រជុំ។ ផ្នែកលិខិតបទដ្ឋានគតិយុត្ត ក៏ធ្វើការទំនាក់ទំនង និងកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីបំពេញការងាររបស់ខ្លួន។ ការធ្វើនូវទំនាក់ទំនងនេះគឺដើម្បីធ្វើការប្រមូលរាល់ឯកសារ និងទិន្នន័យណាដែលមានសារៈសំខាន់ ហើយទាក់ទងនឹងការងាររបស់ខ្លួន។ ផ្នែកលិខិតបទដ្ឋានគតិយុត្ត ក៏ធ្វើការសម្របសម្រួលផងដែរទៅលើការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី១ និងតាមដានសេចក្តីព្រាងឯកសារលិខិតបទដ្ឋានគតិយុត្តដែលបានឆ្លងកិច្ចប្រជុំលើកទី១នោះ។ ផ្នែកលិខិតបទដ្ឋានគតិយុត្តក៏រៀបចំនូវវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តផងដែរ។ រាល់សេចក្តីព្រាងច្បាប់មិនមែនសុទ្ធតែមានផលវិជ្ជមានទាំងអស់នោះទេ ប៉ុន្តែក៏មាននូវបញ្ហាអវិជ្ជមាន ឬក៏ផលប៉ះពាល់មួយចំនួនផងដែរ។ ផ្នែកលិខិតបទដ្ឋានគតិយុត្ត ក៏ធ្វើការរៀបចំតាក់តែងឯកសារលិខិតបទដ្ឋានគតិយុត្ត

[24] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ២៤៨អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា១១។

តាមការកំណត់របស់ ក.ស.វ.។ បន្ថែមពីនេះទៀត ផ្នែកលិខិតបទដ្ឋានគតិយុត្ត ក៏ធ្វើការបំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ ក.ស.វ. ផងដែរ។ [25]

## ២.៤.៦. ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន

ការគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មានជាផ្នែកមួយដែលមានតួនាទីសំខាន់នៅក្នុងការរៀបចំនូវប្រព័ន្ធឯកសារឱ្យមានរបៀបរៀបរយបានល្អប្រសើរ។ ផ្នែកនេះទៀតសោតក៏មានតួនាទីសំខាន់ៗដូចជាៈ ធ្វើការចងក្រងឯកសារលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានតាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានមួយដែលមានលក្ខណៈសមស្រប។ ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មានក៏ធ្វើការងារចងក្រងទិន្នន័យព័ត៌មាន ពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានពីក្រសួងស្ថាប័ន ឬពីប្រភពដទៃផ្សេងៗទៀត។ ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មានក៏ធ្វើការរៀបចំនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ ក.ស.វ. បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ មិនតែប៉ុណ្ណោះ ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មានក៏បង្កើត និងមើលការខុសត្រូវទៅលើគេហទំព័ររបស់ ក.ស.វ. ផងដែរ។ ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន ក៏មានតួនាទីក្នុងការរៀបចំ និងគ្រប់គ្រងបណ្ណាល័យសម្រាប់តម្រូវការឯកសាររបស់ ក.ស.វ. និងបំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ ក.ស.វ. ។ [26]

## ២.៤.៧. ផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ

ផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅៈ ធ្វើការរៀបចំប្រព័ន្ធទំនាក់ទំនង និងកិច្ចសហការជាមួយសង្គមស៊ីវិល ផ្នែកឯកជនអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មានលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងត្រូវមានទំនាក់ទំនងយ៉ាងល្អជាមួយសង្គមស៊ីវិល និងផ្នែកឯកជនព្រមទាំងដៃគូអន្តរជាតិដើម្បីធ្វើការប្រមូលទិន្នន័យផ្សេងៗមកធ្វើការរួមបញ្ចូលគ្នា ជាមួយទិន្នន័យដែលខ្លួនមានហើយដែលទាក់ទងនឹងវិស័យរបស់ខ្លួន។ ផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិក៏ធ្វើការស្វែងរកដៃគូផ្តល់ជំនួយទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសដើម្បីឱ្យការអនុវត្តនូវសកម្មភាពការងាររបស់ ក.ស.វ.

[25] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា១២។

[26] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៤អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា១៣។

ដំណើរការបានល្អប្រសើរសមស្របតាមតម្រូវការរបស់សង្គម។ ហើយផ្នែកនេះក៏ធ្វើការទំនាក់ទំនងរកអ្នកជំនាញការអន្តរជាតិ ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌សម្រាប់ជួយការងារជាទីប្រឹក្សាបច្ចេកទេសជូន ក.ស.វ. និងធ្វើការរៀបចំនូវរាល់អង្គសិក្ខាសាលា ព្រមទាំងធ្វើជាបទបង្ហាញស្តីអំពីការងាររបស់ខ្លួនទាក់ទងទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។[27]

## ២.៥. សមិទ្ធផល និងស្នាដៃរបស់ ក.ស.វ.

### ២.៥.១. សកម្មភាព និងការងាររបស់ ក.ស.វ. ប្រចាំខែ ធ្នូ ឆ្នាំ ២០១៤

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានធ្វើសកម្មភាពការងារនានាជាច្រើនដូចជាធ្វើការវិភាគលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំងធ្វើការចងក្រងទិន្នន័យនៃលិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំឡើងដោយក្រសួងស្ថាប័នពាក់ព័ន្ធនានាជាដើម។ ក្រៅពីនេះទៀត ក.ស.វ. ក៏បានធ្វើការងារមួយចំនួនផ្សេងទៀត ដែលគួរអោយកត់សម្គាល់ផងដែរនៅក្នុងខែ ធ្នូ ឆ្នាំ ២០១៤។

#### ក. សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)

កាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីបានបើកនូវអង្គប្រជុំជំនាញបច្ចេកទេសក្រោមអធិបតីភាព ឯកឧត្តម ឌុយ ធៅ អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម អ៊ុំ ប៊ុនធឿន សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ជាសហប្រធានអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក មន្ត្រី និងតំណាងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី សុខ អាន និងមន្ត្រីជំនាញមួយចំនួននៃទីស្តីការគណៈរដ្ឋមន្ត្រី។

វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលហៅថា វិធីសាស្ត្រ RIA (RIA – Regulatory Impact Assessment) ត្រូវបាននឹងកំពុងអនុវត្តជាផ្លូវការនៅក្នុងប្រទេសចំនួនជាង ៦០ លើពិភពលោកហើយប្រទេសដែលបានអនុវត្តនូវនីតិវិធីនៃការវាយតម្លៃលើលិខិតបទដ្ឋាន

[27] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៩អនក្រ/បក, ០៣ មីនា ២០០៩, មាត្រា១៤។

គតិយុត្តមុនគេនៅអាស៊ានគឺ ប្រទេសវៀតណាម ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០៩។[28] ប្រទេសដែលបានអនុវត្តទាំងនោះ បានទទួលស្គាល់គុណតម្លៃនៃវិធីសាស្ត្រនេះថាជាវិធីសាស្ត្រមួយសម្រាប់វិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តទាំងនោះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដែលជាកត្តាមួយជួយលើកកម្ពស់នូវផលិតភាព និងការប្រកួតប្រជែង។ [29]

នៅកម្ពុជាពុំទាន់មានបទបញ្ញត្តិណាតម្រូវឱ្យមានការអនុវត្តវិធីសាស្ត្រ RIA ជាផ្លូវការនៅឡើយទេ តែបានធ្វើការអនុវត្តសាកល្បងនូវវិធីសាស្ត្រ RIA ជាង៣ឆ្នាំមកហើយ គឺចាប់តាំងពីខែតុលា ឆ្នាំ២០១១ ក្រោមគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថាគម្រោង RIA ក្រោមហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លេខ ០២២៥-CAM (SF) ដែលជាអនុគម្រោងក្រោមកម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច [30] បន្ទាប់ពីកម្មវិធីកំណែទម្រង់ដែលបានអនុវត្តក្នុងកម្មវិធី PED-SP2 (Promoting Economic Diversification-Subprogram 2) ។ ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី បាននឹងកំពុងប្រតិបត្តិការគម្រោងនេះដែលមានក្រសួងចំនួន៧ ចូលរួមអនុវត្តគម្រោងដែលក្នុងនោះរួមមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងទាំងប្រាំពីរបានសម្រេចរបាយការណ៍វាយតម្លៃបឋម និងពេញលេញបានចំនួន៦ ទៀតផង។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយល់ព្រមជាគោលការណ៍ឱ្យ ក.ស.វ. រៀបចំសេចក្តីព្រាងបទបញ្ញត្តិស្តីពីការដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត សំរាប់វាយតម្លៃលើផលប៉ះពាល់នៃសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងនោះ។

សព្វថ្ងៃនេះក្រសួង ស្ថាប័នដែលជាអ្នកមានតួនាទី ឬជំនាញក្នុងការរៀបចំតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត បន្ទាប់ពីខ្លួនបានរៀបចំរួចរាល់ហើយ ត្រូវបញ្ជូនសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនោះមកទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីបើកអង្គប្រជុំ ដោយមានភ្ជាប់មកជាមួយនូវលិខិតបទដ្ឋានមួយចំនួន និងឯកសារយោង ប៉ុន្តែឯកសារទាំងនោះមិនបានធ្វើការវាយតម្លៃលើផលប៉ះពាល់នៃសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនោះទៅតាមវិធីសាស្ត្រ RIA ទេដោយហេតុនេះ

[28] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ព្រឹត្តិបត្រព័ត៌មាន សកម្មភាពការងារ*, ឆ្នាំទី០៧ លេខ ១២ (២០១៤), ១។
[29] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ព្រឹត្តិបត្រព័ត៌មាន សកម្មភាពការងារ*, ឆ្នាំទី០៧ លេខ ១២ (២០១៤), ១។
[30] ពិពិធកម្ម (គុ.) ដែលធ្វើអោយមានច្រើនបែប ច្រើនយ៉ាង។

ហើយទើប ក.ស.វ. ធ្វើការពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តណាដែលឆ្លងកាត់ទីស្តីការ-គណៈរដ្ឋមន្ត្រីដោយធ្វើការវាយតម្លៃ និងពិនិត្យនូវផលប៉ះពាល់ទៅលើសេដ្ឋកិច្ច និងសង្គមកិច្ច ដែលនៅមានកម្រិតនៅឡើយ ព្រោះការប្រមូលព័ត៌មានពីក្រសួងស្ថាប័នគឺនៅមានកង្វះខាត។ ក.ស.វ. ក៏បានធ្វើការកែលម្អ និងបានកាត់បន្ថយនូវចំណុចអវិជ្ជមានមួយចំនួន នៅក្នុងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផងដែរ។ តែការដាក់បញ្ញត្តិឱ្យអនុវត្តវិធីសាស្ត្រ RIA ក្នុងដំណើររៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត មានគោលបំណងលើកកម្ពស់គុណភាពនៃលិខិតបទដ្ឋានគតិយុត្ត កាត់បន្ថយហានិភ័យ ការិយាធិបតេយ្យ និងបន្ទុកចំណាយកាតព្វកិច្ចដែលមិនចាំបាច់ដើម្បីជំរុញការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងរួមចំណែកលើកកម្ពស់ផលិតភាព និងសមធម៌សង្គម ដោយក្រសួងសាមីជាអ្នករៀបចំឡើង។

ចំពោះគម្រោងនេះគឺត្រូវបានផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងមន្ត្រីជំនាញទាំង ២៧ ក្រសួង ស្ថាប័ន និស្សិតមួយចំនួនមកពី ៦ឧត្តមសិក្សា និងតំណាងដៃគូអភិវឌ្ឍន៍ចំនួន៧។ បន្ទាប់មកក្រុមការងារ RIA នៃ ក.ស.វ. បានសហការជាមួយបណ្តាក្រសួងស្ថាប័ន និងអង្គការដែលពាក់ព័ន្ធនានារៀបចំជាសិក្ខាសាលាផ្សព្វផ្សាយ ពិគ្រោះយោបល់អំពីគម្រោងបានចំនួន ៣២ ដងដែលអ្នកចូលរួមប្រមាណជាង ៩៥០០នាក់។ មន្ត្រីគម្រោង RIA នៃ ក.ស.វ. ក៏បានបណ្តុះបណ្តាលមន្ត្រីនៃក្រសួងដែលចូលរួមអនុវត្ត RIA នៅក្នុងគម្រោងទាំងអស់បានចំនួន ៩០នាក់។

ចំពោះការអនុវត្តវិធីសាស្ត្រ RIA ក្នុងដំណើរការព្រាងលិខិតបទដ្ឋានគតិយុត្តនឹងនាំមកនូវអត្ថប្រយោជន៍ជាច្រើនដូចជា៖ ១. ការពង្រឹងអភិបាលកិច្ចល្អ និងជំរុញតម្លាភាព ២. ធ្វើឱ្យសាធារណៈជនមានសេចក្តីទុកចិត្តលើ ប្រព័ន្ធលិខិតបទដ្ឋានគតិយុត្ត និងការគោរពច្បាប់ក៏កាន់តែប្រសើរឡើង។ ៣. ដើម្បីជៀសវាងនូវការជាន់សមត្ថកិច្ចគ្នា ៤. ទប់ស្កាត់នូវសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តណាដែលមានគុណភាពទាបមុននឹងដាក់ជូនអ្នកធ្វើសេចក្តីសម្រេច។ ៥. ដើម្បីកាត់បន្ថយនូវហានិភ័យ ការិយាធិបតេយ្យ និងបន្ទុកចំណាយកាតព្វកិច្ចដែលមិនចាំបាច់ សម្រាប់ប្រយោជន៍សេដ្ឋកិច្ចជាតិ និងគោលនយោបាយសាធារណៈ។ ៦. កាត់បន្ថយនូវបន្ទុកនៃការចំណាយ និងពេលវេលាក្នុងការពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត។

### ខ. កិច្ចប្រជុំត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ

កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីបានបើកកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយទៅលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងមានការចូលរួមពីឯកឧត្តម ឱុយ ផៅ អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ឯកឧត្តម សយ សុខា អគ្គលេខាធិការរាជរដ្ឋាភិបាល និងបណ្តាក្រសួងស្ថាប័នមួយចំនួនទៀតដែលពាក់ព័ន្ធ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ។

កិច្ចប្រជុំនេះបានពិភាក្សាទៅលើសេចក្តីព្រាងច្បាប់យ៉ាងលម្អិតនៅក្នុងមាត្រា២៥ ស្តីពីសិទ្ធិកំណែនដើម្បីប្រតិបត្តិការសង្គ្រោះបន្ទាន់ ដើម្បីឱ្យសមស្របតាមមាត្រា៤៤ និងមាត្រា៦០នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំនេះគឺមានការកែប្រែនូវពាក្យពេចន៍នៅក្នុងមាត្រាមួយចំនួនដូចជា៖ មាត្រា៦ កថាខណ្ឌទី២ បន្ទាត់ទី១ ត្រូវបានលុបនូវពាក្យ "ត្រូវបានតែងតាំង" បន្ទាប់ពីពាក្យ "នាយករដ្ឋមន្ត្រី", មាត្រា៧ កថាខណ្ឌទី២ បន្ទាត់ទី៣ បានបន្ថែមពាក្យថា "អាវុធហត្ថ" បន្ទាប់ពីពាក្យ "នគរបាលជាតិ", មាត្រា១០ បន្ទាត់ទី៣ បានកែសម្រួលឃ្លា "កសាងបញ្ញត្តិ" ទៅជា "កសាងលិខិតបទដ្ឋានគតិយុត្ត" ពីមុខពាក្យ "និងវិធានការពង្រឹង", មាត្រា១៥ បានបន្ថែមពាក្យ "និង" បន្ទាប់ពីពាក្យ "ទប់ស្កាត់", មាត្រា២០ កថាខណ្ឌទី២ បន្ទាត់ទី១ បានកែសម្រួលឃ្លា "តួអង្គពាក់ព័ន្ធ" ទៅជា "ភាគីពាក់ព័ន្ធ", នៅចន្លោះពាក្យ "គ្រប់" និងពាក្យ "ពិភាក្សា"។[31]

## ២.៦. ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក្រៅពីសកម្មភាពខាងលើដូចជា ការធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ និងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ។ ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា និងការចងក្រងសៀវភៅស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ និងប្រចាំឆ្នាំ ក៏ជាផ្នែកមួយនៃស្នាដៃ និងសមិទ្ធផលដែល ក.ស.វ. បាននឹងកំពុងធ្វើ និងសម្រេចបាននាឆ្នាំនីមួយៗផងដែរ។ ដោយឡែកក្នុងឆ្នាំ ២០១៤ ក.ស.វ. បានធ្វើការវិភាគលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលមានការវិភាគទៅលើស្ថានភាពទាំងឡាយនៃសេដ្ឋកិច្ចរបស់កម្ពុជាព្រមទាំងវិស័យសង្គមកិច្ច និងវប្បធម៌។

[31] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ព្រឹត្តិបត្រព័ត៌មាន សកម្មភាពការងារ*, ឆ្នាំទី០៧ លេខ ១២ (២០១៤), ៦។

### ២.៦.១. ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ ២០១៤

របាយការណ៍ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងឆ្នាំ២០១៤ គឺជាលទ្ធផលសរុបនៃកិច្ចប្រជុំទូលាយរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានការសហការចូលរួមពីបណ្តាក្រសួង ស្ថាប័ននានាដែលមានការពាក់ព័ន្ធទៅនឹងការវិភាគ ដើម្បីធ្វើការផ្លាស់ប្តូរយោបល់ពីគ្នាទៅវិញទៅមកទៅលើលទ្ធផលនៃការវិភាគ នៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ក្រោយពីធ្វើការផ្លាស់ប្តូរយោបល់គ្នា រួចរាល់លទ្ធផលស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ត្រូវបានលេចចេញជារូបរាងដូចខាងក្រោម។

#### ក. ការវិភាគស្ថានភាពសេដ្ឋកិច្ច

តាមរយៈការវិភាគសេដ្ឋកិច្ច របស់កម្ពុជា ការវិភាគទៅលើស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់បានបង្ហាញឱ្យឃើញថា អត្រាអតិផរណាឆ្នាំ ២០១៤ ស្មើនឹង ៣,៩% ដែលក្នុងនោះក្រុមទំនិញដែលឡើងថ្លៃ លើសពីអត្រាជាមធ្យមរួមមានម្ហូបអាហារ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ គ្រឿងសង្ហារឹម សុខាភិបាល ការសិក្សា និងភោជនីយដ្ឋាន ដែលលើសពីអតិផរណាឆ្នាំ ២០១៣ ប្រមាណជា ០,៩%។ មុខទំនិញមួយចំនួនក៏មានការឡើងថ្លៃខ្ពស់គួរឱ្យកត់សម្គាល់ផងដែរដូចជា ផ្លែឈើ សាច់ជ្រូក សាច់គោស្រស់ និងត្រីស្រស់ដែលមានការឡើងថ្លៃជាមធ្យមចន្លោះប្រមាណជា ៥,៦% ទៅ ៩,៧% នៃអតិផរណា។ [32] ក្នុងនោះមានក្រុមទំនិញមួយចំនួនក៏មានសន្ទស្សន៍ថ្លៃថយចុះផងដែរ ដែលក្នុងនោះរួមមាន ការដឹកជញ្ជូន ទូរគមនាគមន៍ ទំនិញ និងសេវាកម្មផ្សេងៗ។ ចំណែកឯការពិនិត្យទៅលើប្រាក់រៀលរបស់កម្ពុជា អត្រាប្តូរប្រាក់មានការធ្លាក់ចុះបើធៀបទៅនឹងរូបិយប័ណ្ណបរទេស។ នាចុងឆ្នាំ ២០១៤ អត្រាប្តូរប្រាក់រៀលធៀបទៅនឹង រូបិយប័ណ្ណមួយចំនួនមានស្ថានភាពដូចជា ប្រាក់រៀលធ្លាក់ថ្លៃ ២% បើធៀបនឹងប្រាក់ដុល្លាអាមេរិក និងមានអត្រា ៤,០៧៥៛ ក្នុងមួយដុល្លា។ ប្រាក់រៀលធ្លាក់ថ្លៃ ១,៦% បើធៀបនឹងប្រាក់បាតថៃ និងមានអត្រា ១២៤៛ ក្នុងមួយបាតថៃ។ ប្រាក់រៀលធ្លាក់ថ្លៃ ០,៥% បើធៀបនឹងប្រាក់ដុងវៀតណាម និងមានអត្រា ០,១៩១៛ ក្នុងមួយដុងវៀតណាម។ [33] (មើលឧបសម្ព័ន្ធ ៤)

ចំពោះស្ថានភាពថវិកាជាតិ ក.ស.វ. ក៏បានធ្វើការវិភាគ ដោយធ្វើការប្រមូលទិន្នន័យចម្បងពីរតនាគារជាតិ ដែលក្នុងនោះ ចំណូលសម្រាប់ថវិកាជាតិក្នុងឆ្នាំ ២០១៤ មានប្រមាណ ១០៥៣៦,៤ ពាន់លានរៀល ស្មើនឹង ១០៣% នៃច្បាប់ថវិកា ដែលនៅក្នុងនោះចំណូលចរន្តមានចំនួន

[32] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ១។
[33] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ២។

៩២៣៩,៣ ពាន់លានរៀល ដែលស្មើនឹង ១០៩% នៃច្បាប់ថវិកា និងចំណូលមូលធនប្រមាណ ២០០,៨ ពាន់លានរៀល។ បើសិនជាធៀបចំណូលថវិកាជាតិដែលទទួលបានទៅនឹងឆ្នាំ ២០១៣ ចំណូលនេះបានកើនឡើងប្រមាណ ២២% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង ១១% និងចំណូលមូលធនថយចុះ ៤២%។ ការកើនឡើងនូវចំណូលចរន្តជាចម្បងបណ្ដាលមកពីចំណូលសារពើពន្ធ កើនឡើងចំនួន ២៥% និងចំណូលមិនមែនសារពើពន្ធ កើនឡើងចំនួន ២៤%។[34]

សម្រាប់ចំណាយថវិកាជាតិប្រចាំឆ្នាំ ២០១៤ មានប្រមាណ ៨៦៦៤,៤ ពាន់លានរៀល ស្មើនឹង ៦៤% នៃច្បាប់ថវិកា ក្នុងនោះចំណាយចរន្តមានចំនួន ៧១៤៧,៣ ពាន់លានរៀល ស្មើនិង៨៦% នៃច្បាប់ថវិកា និងចំណាយមូលធនមានចំនួន ១៥១៧ ពាន់លានរៀល។ ប្រសិនបើធ្វើការប្រៀបធៀបចំណាយថវិកាជាតិក្នុងឆ្នាំ ២០១៣ កើនឡើងប្រមាណ ២៩,៥% ដែលក្នុងនោះចំណាយចរន្តកើនឡើង ៣២% និងចំណាយមូលធនកើនឡើង ១៧% ។[35] (មើលឧបសម្ព័ន្ធ ៤)

## ខ. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សង្គមកិច្ច និងវប្បធម៌

ក្នុងវិស័យកសិកម្មឆ្នាំ ២០១៤ ផលិតផលស្រូវដែលផលិតបានមានបរិមាណចំនួន ៩២៣៤ ពាន់តោន បើធៀបទៅនឹងឆ្នាំ ២០១៣ មានការថយចុះ ១,៧% រីឯទិន្នផលមានចំនួន ៣,០៥ តោនក្នុងមួយហិចតា បើធៀបទៅនឹងឆ្នាំ ២០១៣ មានការថយចុះ ៣,៥%។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីដែលបានធ្វើការដាំដុះស្រូវទាំងក្នុងរដូវប្រាំង និងរដូវវស្សា មានចំនួន ៣០៥២ ពាន់ហិចតា បើធៀបទៅនឹងឆ្នាំ ២០១៣ មានការកើនឡើងប្រមាណ ១២ ពាន់ហិចតា។ ចំណែកឯ ផលិតផលកៅស៊ូ ក៏មានការកើនឡើងផងដែរ បើធៀបទៅនឹងឆ្នាំ ២០១៣ ពោលគឺមានចំនួន ៩៦,៧ ពាន់តោន ដែលមានការកើនឡើងចំនួន ១៣,៤%។ ហើយចំពោះផ្ទៃដីដែលចៀរជ័រកៅស៊ូ មានចំនួន ៩០,៦ ពាន់ហិចតា និងផ្ទៃដីដាំដុះសរុបមានចំនួន ៣៥៧,៨ ពាន់ហិចតា។ ចំពោះផលនេសាទក្នុងឆ្នាំ ២០១៤ មានចំនួន ៦៧៦ ពាន់តោន នឹងមានការថយចុះ ៥% បើធៀបទៅនឹងឆ្នាំ ២០១៣។[36] (មើលឧបសម្ព័ន្ធ ៤)

ដោយឡែក នៅក្នុងវិស័យឧស្សាហកម្ម ថាមពលអគ្គិសនីដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា មានចំនួន ៤៥៦៩,៩ ជីហ្គាវ៉ាត់ម៉ោង ដែលមានការកើនឡើងចំនួន ២១% ហើយដែលក្នុងនោះ

[34] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ២។

[35] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ៣។

[36] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ៤។

អគ្គិសនីផលិតដោយ វារីអគ្គិសនី មានចំនួន ១៨៤០,៩ ជីហ្គាវ៉ាត់ម៉ោង ដែលមានការកើនឡើងចំនួន ៨៣% បើធៀបទៅនឹងឆ្នាំ ២០១៣។[37] (មើលឧបសម្ព័ន្ធ ៤)

ផលិតកម្មវាយនភណ្ឌ និងស្បែកជើងសម្រេចបានក្នុងតម្លៃប្រមាណ ៥៧១៩,៨ លានដុល្លាសហរដ្ឋអាមេរិក ដែលមានការកើនឡើងចំនួន ១៣% បើធៀបទៅនឹងឆ្នាំ ២០១៣។ ទឹកស្អាតដែលផ្គត់ផ្គង់ដោយរដ្ឋាករទឹក មានចំនួន ១៨៨,២ លានម៉ែត្រគីប ដែលកើនឡើង ៨% បើធៀបទៅនឹងឆ្នាំ ២០១៣។ វិស័យសំណង់ក្នុងឆ្នាំ ២០១៤ មានការថយចុះប្រមាណ ១០% បើធៀបទៅនឹងឆ្នាំ ២០១៣ ពោលគឺមានការសាងសង់ក្នុងទឹកប្រាក់ចំនួន ២៥០៧,២ លានដុល្លាសហរដ្ឋអាមេរិក។ ក្នុងនោះសំណង់ដែលពេញនិយមក្នុងការសាងសង់មានដូចជា លំនៅដ្ឋាន ដែលមានចំនួន ៤៩% នៃផ្ទៃក្រឡាសរុប និងឧស្សាហកម្ម ដែលមានចំនួន ២៦,៧% នៃផ្ទៃក្រឡាសរុប។ នៅក្នុងវិស័យសង្គមកិច្ចក្នុងឆ្នាំ ២០១៤ ការទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន មានប្រមាណ ៧៤២៥៦ នាក់ មានការកើនឡើង ៣៨% បើធៀបទៅនឹងឆ្នាំ ២០១៣។ ក្នុងនោះការទទួលការងារនៅក្នុងប្រទេស មានចំនួន ៥៤២៦៩ នាក់ ដែលមានការកើនឡើង ៦០%។ ឯការទទួលបានការងារនៅក្រៅប្រទេស មានចំនួន ១៩៩៨៧ នាក់ ដែលមានការកើនឡើង ៧% បើធៀបទៅនឹងឆ្នាំ ២០១៣។ ចំពោះវិស័យទេសចរណ៍វប្បធម៌ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានចូលមកទស្សនានៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចំនួន ៤៤៩០ ពាន់នាក់ ដែលមានការកើនឡើង ៧% បើធៀបទៅនឹងឆ្នាំ ២០១៣។ ក្នុងនោះភ្ញៀវទេសចរដែលធ្វើដំណើរតាម ផ្លូវអាកាស មានប្រមាណ ២២៦២ ពាន់នាក់ ដែលមានការកើនឡើង ១២% ហើយភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវគោក និងទឹក មានចំនួន ២២២៨ ពាន់នាក់ ដែលមានការកើនឡើង ២% បើធៀបទៅនឹងឆ្នាំ ២០១៣។[38] (មើលឧបសម្ព័ន្ធ ៤)

តាមរយៈការវិភាគខាងលើ ការសន្និដ្ឋានជារួមគឺ៖ ១. ជារួមអត្រាអតិផរណាឆ្នាំ ២០១៤ មានកម្រិតទាប ក៏ប៉ុន្តែ មុខទំនិញមួយចំនួនដូចជា ផ្លែឈើ សាច់ជ្រូក និងត្រី មានការឡើងថ្លៃគួរឱ្យចាប់អារម្មណ៍។ មូលហេតុនៃការឡើងថ្លៃ បណ្ដាលមកពីការផ្គត់ផ្គង់ក្នុងស្រុកមិនគ្រប់គ្រាន់ជាមូលហេតុចម្បងដែលធ្វើឱ្យ សាច់ បន្លែ និងផ្លែឈើ មានការឡើងថ្លៃខ្ពស់។ ដូចនេះវិស័យចិញ្ចឹមសត្វគួរតែធ្វើការអភិវឌ្ឍឱ្យក្លាយទៅជាកសិដ្ឋានខ្នាតធំ។ ការទាក់ទាញនឹងលើកទឹកចិត្ត អ្នកវិនិយោគក្នុងវិស័យកសិកម្ម និងកសិឧស្សាហកម្មជាការចាំបាច់ដើម្បីបង្កើន ផលិតកម្មក្នុងស្រុក នឹងដើម្បីកាត់បន្ថយនូវការនាំចូល។ ចំពោះច្បាប់វិនិយោគរបស់កម្ពុជាដែលកំពុងមានគួរតែមានការកែតម្រូវខ្លះៗ

[37] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ៤។

[38] ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (ភ្នំពេញ, ២០១៤), ៦។

ទាក់ទងទៅនឹងការលើកទឹកចិត្តដល់អ្នកវិនិយោគខ្នាតធំក្នុងវិស័យនេះ។ ២. ចំណូលសារពើពន្ធបាន អនុវត្តលើសផែនការ ដែលនេះជាលទ្ធផលនៃការអនុវត្តបាន របស់មន្ត្រីពាក់ព័ន្ធតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី និងកិច្ចសហការគ្នាយ៉ាងល្អនៃស្ថាប័នពាក់ព័ន្ធនានា។ ៣. នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសនៅ រាជធានីភ្នំពេញ មានអំពើចោរកម្ម កើតឡើងជាញឹកញាប់ ដូចជា ការឆក់ ប្លន់ ប្រដាប់អាវុធ នៅតាមដងផ្លូវសាធារណៈស្ទើតែរាល់ថ្ងៃ ដែលធ្វើឱ្យមានអ្នករងគ្រោះជាច្រើន មានទាំងប្រជាពលរដ្ឋ និងភ្ញៀវបរទេសដែលចូលមកទស្សនាប្រទេសកម្ពុជា។ បញ្ហានេះពិតជាធ្វើឱ្យប៉ះពាល់ដល់ សតិអារម្មណ៍របស់ប្រជាពលរដ្ឋក៏ដូចជាមុខមាត់ជាតិ ព្រមទាំងសេដ្ឋកិច្ច សង្គមកិច្ច របស់ជាតិទាំងមូលផងដែរ។ ក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ចក្រោមឱវាទគួរតែមានវិធានការដែលមានលក្ខណៈម៉ឺងម៉ាត់បំផុត ក្នុងការរក្សាសន្តិសុខសង្គម សីលធម៌ និងវប្បធម៌ដ៏ថ្លៃថ្នូររបស់ជាតិយើង។

## ២.៧. ទស្សនៈវិស័យរបស់ ក.ស.វ. ចំពោះសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ដោយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាអង្គភាពមួយដែលធ្វើការងារពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយបានធ្វើការវិភាគ និងប្រមូលនូវទិន្នន័យក៏ដូចជាព័ត៌មានយ៉ាងច្រើនសម្បូរបែបសម្រាប់ការវិភាគ និងសិក្សាពីបណ្ដាក្រសួងស្ថាប័ននានាដែលមានការពាក់ព័ន្ធ។ ហេតុនេះទស្សនៈវិស័យគឺជាផ្នែកមួយមិនអាចខ្វះបានសម្រាប់ការអនុវត្តនូវការងារនាថ្ងៃអនាគត។

ម្យ៉ាងទៀតតាមរយៈសកម្មភាព RIA ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មានទស្សនៈវិស័យយ៉ាងទូលំទូលាយចំពោះការងាររបស់ខ្លួន។ ក.ស.វ. មានបំណង ក្នុងការពង្រឹងឱ្យលិខិតបទដ្ឋានគតិយុត្ត មានលក្ខណៈអោយកាន់តែល្អប្រសើរ។[39] ភាពល្អប្រសើរនៃលិខិតបទដ្ឋានគតិយុត្តមិនមែនល្អប្រសើរត្រឹមតែអត្ថន័យ និងខ្លឹមសារនៃគតិយុត្តប៉ុណ្ណោះទេ ប៉ុន្តែវាជាការចាំបាច់ក្នុងការសិក្សាឱ្យបានល្អិតល្អន់ទៅលើផលប៉ះពាល់នានាដែល អាចកើតមានឡើង តាមរយៈការអនុវត្តនូវបទដ្ឋានគតិយុត្តនោះ ថាតើមានផលប៉ះពាល់កម្រិតណាហើយនរណាខ្លះដែលទទួលរងនូវផលប៉ះពាល់ពីការអនុវត្តនោះ ព្រោះថារាល់គតិយុត្តទាំងអស់មិនមែនសុទ្ធតែមានផលវិជ្ជមានទាំងអស់នោះទេ ហេតុនេះហើយការសិក្សា និងវាយតម្លៃដោយប្រើប្រាស់វិធីសាស្ត្រ RIA ក្នុងការស្វែងរកនូវផលប៉ះពាល់ទាំងនោះពិតជាមានការចាំបាច់។ ម្យ៉ាងវិញទៀតបទដ្ឋានគតិយុត្តទាំងនោះ គួរតែ

[39] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ុង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

មានសុក្រឹតភាព និងភាពច្បាស់លាស់នៅក្នុងការអនុវត្ត។[40] បទដ្ឋានគតិយុត្តជាឧបករណ៍មួយដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងសង្គម សេដ្ឋកិច្ច ឱ្យរីកចម្រើន ជំរុញអភិបាលកិច្ចល្អ ធុរកិច្ចឱ្យរីកលូតលាស់ និងងាយស្រួលដល់ការអនុវត្ត ។ ហេតុនេះហើយសុក្រឹតភាព និងភាពច្បាស់លាស់ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តចាំបាច់ត្រូវតែមាន ព្រោះថាបើការអនុវត្តបទដ្ឋានគតិយុត្តមានការខ្វះចន្លោះនោះលទ្ធផលការងារដែលពាក់ព័ន្ធ ប្រាកដជាមិនសូវមានលទ្ធផលខ្ពស់ប៉ុន្មាននោះទេ។

ក្រៅពីទស្សនៈវិស័យចំពោះ RIA ក្នុងការធ្វើឱ្យប្រសើរឡើងនូវលិខិតបទដ្ឋានគតិយុត្តនានា ក.ស.វ. ក៏មាននូវទស្សនៈវែងឆ្ងាយផងដែរចំពោះវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជាដើម្បីឱ្យមានការរីកចម្រើន និងលូតលាស់ទៅមុខជាលំដាប់។ [41] តាមរយៈការវិភាគនូវស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវកំណើន ក៏ដូចជាការថយចុះទាំងអស់ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចនេះតាមរយៈកំណើន និងការថយចុះនេះ ក.ស.វ. អាចផ្តល់ជាយោបល់ និងសំណើនានាជូនរាជរដ្ឋាភិបាលដើម្បីធ្វើការកែតម្រូវនូវបញ្ហានានាដែលបណ្តាលឱ្យមានការថយចុះនៅក្នុងវិស័យនីមួយៗ។ លើសពីនេះទៀតការជំរុញឱ្យគ្រប់ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ធ្វើការផ្តល់នូវទិន្នន័យសម្រាប់បម្រើឱ្យការវិភាគឱ្យបានទាន់ពេលវេលា គឺពិតជាសំខាន់ព្រោះបើទិន្នន័យទាំងអស់ ត្រូវបានប្រគល់ឱ្យ ក.ស.វ. បានទាន់វេលាពេលនោះការវិភាគនឹងមានលក្ខណៈល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងដើរទាន់សភាពការណ៍របស់សង្គមផងដែរ។

---

[40] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ុង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

[41] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ុង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

# ជំពូកទី ៣

# ការវិភាគលើការអនុវត្តការងាររបស់ ក.ស.វ.

ក្រោយពីបានធ្វើការសិក្សាទៅលើការអនុវត្តការងារនៃ ក.ស.វ. តាមរយៈសកម្មភាពដែលបានកំណត់ក្នុងព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏ដូចជានៅក្នុងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងព្រឹត្តិបត្រព័ត៌មានស្តីពីសកម្មភាពការងារ និងការវិភាគទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌រួចមក ការវិភាគលើការអនុវត្តការងាររបស់ ក.ស.វ. ពិតជាមានការចាំបាច់។ ការវិភាគនេះនឹងធ្វើការសិក្សាទៅលើការអនុវត្តការងាររបស់ ក.ស.វ. ដោយផ្អែកទៅលើគោលការណ៍ទាំង ៩ នៃអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ ព្រមទាំងស្វែងរកនូវបញ្ហាប្រឈមក៏ដូចជាការផ្តល់នូវដំណោះស្រាយផ្សេងៗដែលមានលក្ខណៈសមស្របផងដែរ។

## ៣.១. ការអនុវត្តការងារនៃ ក.ស.វ.

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រីហើយដែលមានតួនាទីកំណត់នៅក្នុងព្រះរាជក្រឹត្យ និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការក្នុងការធ្វើឱ្យដំណើរការងារមានលក្ខណៈល្អប្រសើរ។ ក.ស.វ. បានធ្វើកិច្ចការងារជាច្រើនដូចអ្វីដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យ ព្រមទាំងការងារមួយចំនួនទៀតផងដែរ ក្នុងគោលដៅតែម្យ៉ាងគត់គឺបម្រើនូវផលប្រយោជន៍សង្គម ក៏ដូចជាជួយរាជរដ្ឋាភិបាលក្នុងការធ្វើការងារដែលពាក់ព័ន្ធឱ្យកាន់តែមានភាពល្អប្រសើរទៅមុខជាលំដាប់។

នៅក្នុងកិច្ចការជាច្រើនដែលបានធ្វើឡើងដោយ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌គឺឃើញថាមានការចូលរួមពីសំណាក់ អ្នកពាក់ព័ន្ធទាំងអស់ដូចជាក្រសួងនានា ដែលបានផ្តល់ទិន្នន័យមកកាន់ ក.ស.វ. ដើម្បីធ្វើការវិភាគចេញជា របាយការណ៍ស្តីពីការវិភាគទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឱ្យមានភាពសុក្រឹត និងល្អប្រសើរ។ មិនតែប៉ុណ្ណោះនៅក្នុងគម្រោង RIA ដែលជាផ្នែកមួយនៃសកម្មភាពការងាររបស់ ក.ស.វ. ផងដែរនោះ ក៏មានការចូលរួមពីសំណាក់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការផ្តល់ជាជំនួយឥតសំណងក្នុងការដំណើរការកម្មវិធីនេះដើម្បីធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តរបស់កម្ពុជា តាមរយៈការកាត់បន្ថយ ឱ្យផលប៉ះពាល់នៃបទដ្ឋានគតិយុត្តទាំងនោះឱ្យស្ថិតនៅក្នុងកម្រិតអប្បបរិមាមួយដែលគ្រប់ភាគីអាចទទួលយកបាន។

បើសិនជាក្រឡេកទៅមើលលើ គោលការណ៍នីតិរដ្ឋ នៅក្នុងការអនុវត្តការងាររបស់ ក.ស.វ. វិញគឺមានលក្ខណៈល្អប្រសើរព្រោះថា ក.ស.វ. ជាអង្គភាពមួយដែលបានបង្កើតដោយឯកសារច្បាប់ ហើយត្រូវបានកំណត់តួនាទីយ៉ាងច្បាស់លាស់នៅក្នុងក្របខណ្ឌច្បាប់ហេតុនេះហើយទើប ក.ស.វ. បានធ្វើការអនុវត្តការងារទាំងឡាយ ដែលស្ថិតនៅក្នុងក្របខណ្ឌនៃសកម្មភាពរបស់ខ្លួនបានយ៉ាងល្អប្រសើរ។ ដោយក្នុងនោះផងដែរ ក.ស.វ. ក៏មានប្រព័ន្ធទទួលខុសត្រូវមួយច្បាស់លាស់ទៅលើសកម្មភាពរបស់ខ្លួនដែលបានធ្វើ តាមរយៈការរាយការណ៍ទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី ពាក់ព័ន្ធទៅនឹងការងារនានាដែលខ្លួនបានធ្វើដូចជាការវិភាគ និងសកម្មភាពផ្សេងៗជាដើម។

នៅក្នុងគោលការណ៍នៃការព្រមព្រៀងឯកភាពគ្នា ក.ស.វ. បានធ្វើការងារប្រកបទៅដោយលក្ខណៈពិសេសមួយ ដែលក្នុងនោះមានការពិចារណាយ៉ាងទូលំទូលាយហើយមានលក្ខណៈវែងឆ្ងាយទៅលើការងារព្រមទាំងប្រយោជន៍ និងតម្រូវការរបស់សង្គម ដើម្បីជ្រើសរើស និងស្វែងរកនូវវិធីណាដែលអាចបម្រើដល់ប្រយោជន៍សាធារណៈបាន។ ដូចដែលបានឃើញតាមរយៈសកម្មភាពការងារនៃការវិភាគនូវស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលធ្វើឡើងដោយយោងទៅលើទិន្នន័យដែលទទួលបានពីបណ្តាក្រសួងនានានោះ ការប្រជុំត្រូវបានធ្វើឡើងនៅពេលដែលទិន្នន័យទាំងនោះមានភាពមិនប្រក្រតី ឬមិនឆ្លើយតបទៅតាមតម្រូវការរបស់សង្គមជាតិជាដើម ពេលនោះហើយដែលការជជែកគ្នា ស្វែងរកនូវវិធីណាមួយដើម្បីធ្វើឱ្យមានការឯកភាពគ្នា ក្នុងកិច្ចការងារនោះត្រូវបានធ្វើឡើង។

ចំពោះគោលការណ៍សមធម៌វិញ តាមរយៈសកម្មភាព RIA របស់ ក.ស.វ. ត្រូវបានយកចិត្តទុកដាក់ជាខ្លាំង។ ការកាត់បន្ថយនូវការប៉ះពាល់របស់បទដ្ឋានគតិយុត្ត មិនមែនធ្វើឡើងសម្រាប់តម្រូវតែក្រុមណាមួយនៅក្នុងសង្គមនោះទេ ប៉ុន្តែការកាត់បន្ថយនេះគឺធ្វើឡើងដើម្បីគ្រប់ក្រុមទាំងអស់នៅក្នុងសង្គម ហើយដែលអាចទទួលយកបានព្រោះថាជាទូទៅ រាល់គតិយុត្តតែងតែមានផលប៉ះពាល់ទៅលើក្រុមនីមួយៗ គ្រាន់តែតិចហើយនិងច្រើនតែប៉ុណ្ណោះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏គម្រោង RIA នឹងធ្វើការកាត់បន្ថយឱ្យផលប៉ះពាល់នៃគតិយុត្តទៅលើគ្រប់ក្រុមទាំងអស់ស្ថិតនៅក្នុងកម្រិតមួយតិចបំផុត។

ដោយឡែកចំពោះប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៅក្នុងការអនុវត្តការងាររបស់ ក.ស.វ. មានភាពល្អប្រសើរច្រើន ព្រោះថាធ្វើការពិនិត្យទៅលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ការិយាធិបតេយ្យនៃរចនាសម្ព័ន្ធដឹកនាំមិនត្រូវបានអនុវត្តហើយការប្រើប្រាស់នូវធនធានទាំងឡាយរបស់អង្គភាព មានលក្ខណៈត្រឹមត្រូវ ដោយរាប់បញ្ចូលទាំងធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈ បានអស់លទ្ធភាព និងមានការសន្សំសំចៃខ្ពស់ ហើយមិនតែប៉ុណ្ណោះ

ថែមទាំងបានបង្កើតជាលទ្ធផលនៃការងារ ដែលមានគុណភាពខ្ពស់ និងបានបម្រើប្រយោជន៍ជាអតិបរមាព្រមទាំងតម្រូវការពិតរបស់សង្គមថែមទៀតផង។

ដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាព ការអនុវត្តការងាររបស់ ក.ស.វ. ត្រូវបានធ្វើឡើងប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត។ ក.ស.វ. បានធ្វើការងារជាច្រើនក្នុងនាមជាជំនួយការរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យ វិស័យដែលខ្លួនទទួលខុសត្រូវមានភាពល្អប្រសើរ និងរីកចម្រើនទៅមុខ ស្របតាមការវិវត្តនៃប្រទេសជាតិ។ ក្នុងការអនុវត្តកិច្ចការងារនោះដែរ ក.ស.វ. តែងតែធ្វើការរាយការណ៍ជាប្រចាំ និងពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងសកម្មភាពការងាររបស់ខ្លួន និងបានផ្សព្វផ្សាយជាសាធារណៈផងដែរ។

តាមរយៈគោលការណ៍នៃការឆ្លើយតប ការអនុវត្តការងាររបស់ ក.ស.វ. បានឆ្លើយតបយ៉ាងច្រើនពាក់ព័ន្ធទៅនឹងតម្រូវការរបស់សង្គមជាតិទាំងមូល។ ក្នុងនោះ ក.ស.វ. បានព្យាយាម និងខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធ្វើយ៉ាងណា ឱ្យការងាររបស់ខ្លួនពិតជាបានបម្រើនូវប្រយោជន៍សង្គមជាតិក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់។ តាមរយៈការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ ក.ស.វ. ពិតជាបានផ្តល់ផលវិជ្ជមានជាច្រើនដល់សង្គមជាតិ ដូចជាផ្តល់នូវព័ត៌មានទាក់ទងទៅនឹងការវិវត្តនៃ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជា ដល់ពលរដ្ឋឱ្យបានយល់ដឹង និងស្វែងយល់។ បន្ថែមពីនេះទៅទៀតការវិភាគនេះ ក៏បានផ្តល់ជាព័ត៌មានផងដែរទៅកាន់អ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកទាំងអស់ដែលអាចប្រើប្រាស់នូវរាល់ព័ត៌មានទាំងនេះដើម្បីបម្រើឱ្យការវិនិយោគរបស់ខ្លួន ក៏ដូចជាធ្វើឱ្យវិស័យវិនិយោគនៅកម្ពុជា មានភាពល្អប្រសើរផងដែរ។ ជាពិសេសការវិភាគនោះពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់ សម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ដើម្បីឱ្យការសម្រេចចិត្តនោះប្រកបទៅដោយ ភាពត្រឹមត្រូវ និងសមស្របតាមគោលនយោបាយជាតិដែលបានដាក់ចេញនៅក្នុងអាណត្តិនីមួយៗផងដែរ។

បើសិនជាក្រឡេកទៅមើលលើ ចក្ខុវិស័យជាយុទ្ធសាស្ត្រ នៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌វិញឃើញថា ក.ស.វ. ពិតជាមានចក្ខុវិស័យយ៉ាងវែងឆ្ងាយពាក់ព័ន្ធទៅនឹងកិច្ចការដែលខ្លួនកំពុងធ្វើ ក៏ដូចជាទស្សនៈវិស័យសម្រាប់ពេលអនាគតពាក់ព័ន្ធទៅនឹងអភិបាលកិច្ចល្អផ្ទៃក្នុង ក៏ដូចជាការអភិវឌ្ឍធនធានមនុស្ស របស់អង្គភាពផ្ទាល់ដើម្បីបង្កើននូវសមត្ថភាពរបស់បុគ្គលិកក្នុងការអនុវត្តការងារ។ តាមរយៈការវិភាគលើ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក.ស.វ. មានចក្ខុវិស័យតែមួយគត់គឺការធ្វើឱ្យសង្គមជាតិមានការរីកចម្រើន និងអាចផ្តល់ជាយោបល់ជូនរាជរដ្ឋាភិបាល តាមដែលអាចធ្វើទៅបាន។ ដោយឡែកនៅក្នុងគម្រោង

RIA របស់ ក.ស.វ. ទស្សនៈវិស័យដែលត្រូវបានដាក់ចេញគឺធ្វើយ៉ាងណាឱ្យលិខិតបទដ្ឋានគតិយុត្ត ទាំងអស់របស់កម្ពុជាមានលក្ខណៈល្អប្រសើរសម្រាប់ការអនុវត្ត និងមានផលប៉ះពាល់តិចបំផុត។

### ៣.២. បញ្ហាប្រឈម

ទោះបីជាការអនុវត្តការងាររបស់ ក.ស.វ. មានភាពល្អប្រសើរច្រើនដោយយោងទៅលើវិភាគ តាមគោលការណ៍នៃ អភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ ប៉ុន្តែបញ្ហាប្រឈមនានាប្រាកដជាកើត មានទាំងនៅក្នុងការអនុវត្តការងារព្រមទាំងសកម្មភាពការងារផ្សេងៗរបស់ ក.ស.វ. ផងដែរ។

បញ្ហាប្រឈមដែល ក.ស.វ. បានជួបប្រទះនៅក្នុងការវិភាគសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺកង្វះទិន្នន័យពីបណ្ដាក្រសួងនានា ដែលមានតួនាទីនៅក្នុងការផ្ដល់នូវទិន្នន័យទាំងនោះ។[42] ក្នុង ការផ្ដល់ទិន្នន័យមកកាន់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពេលខ្លះគឺមិនមានភាព គ្រប់គ្រាន់ និងមិនគ្រប់ជ្រុងជ្រោយដែលធ្វើឱ្យ ក.ស.វ. ពិបាកនៅក្នុងការវិភាគនូវទិន្នន័យទាំងនោះ ដែលអាចនាំទៅរកភាពមិនប្រក្រតីសម្រាប់ការវិភាគ និងមានមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ផ្សេងពីនេះទៀតក្នុងការផ្ដល់ទិន្នន័យនានាមកកាន់ ក.ស.វ. ពីបណ្ដាក្រសួងស្ថាប័នដែលពាក់ព័ន្ធ មានលក្ខណៈមិនទាន់ពេលវេលាដែលជាមូលហេតុចម្បង នាំទៅរកភាពយឺតយ៉ាវនៃការវិភាគដែល ធ្វើឱ្យរបាយការណ៍នៃការវិភាគនោះមិនបម្រើឱ្យស្ថានភាពសង្គមបានទាន់ពេលវេលា និងតម្រូវការ នៃសង្គមជាតិទាំងមូល។

បញ្ហាប្រឈមមួយទៀតផងដែរដែល ក.ស.វ. បានជួបប្រទះនៅក្នុងការអនុវត្តការងារ RIA នោះគឺ កង្វះនូវឆន្ទៈរបស់អ្នកដែលមានសិទ្ធិសម្រេចរបស់ក្រសួងខ្លះ ក្នុងការអនុវត្តកម្មវិធី RIA ។[43] អ្នកដែលមានសិទ្ធសម្រេចខ្លះ គឺមិនបានជ្រួតជ្រាបពីអត្ថប្រយោជន៍ និងសកម្មភាពនៃកម្មវិធី RIA ដែលបណ្ដាលឱ្យមានជាភាពរារែក និងមិនមានការជំរុញដល់ការអនុវត្ត RIA នៅក្នុងក្រសួង។ មិនតែប៉ុណ្ណោះការធ្វើការងារពាក់ព័ន្ធទៅដល់សកម្មភាពនៃកម្មវិធី RIA របស់ក្រសួងនានាដែលស្ថិត នៅក្នុងគម្រោង RIA គឺនៅមានកម្រិតទៅលើគុណភាពនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិត បទដ្ឋានគតិយុត្តរបស់ខ្លួន ដែលបណ្ដាលមកពីកង្វះធនធានមនុស្សដែលគម្រោង RIA តម្រូវឱ្យមាន នូវការយល់ដឹងខ្ពស់ពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច សង្គម និងគោលនយោបាយ ក្រៅពីជំនាញច្បាប់ និង ជំនាញនៅក្នុងក្រសួង។

---

[42] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ិង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

[43] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ិង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

ក្រៅពីបញ្ហាប្រឈមខាងលើក៏នៅមាន បញ្ហាផ្សេងៗមួយចំនួនទៀតដូចជា កង្វះនូវថវិកាសម្រាប់បម្រើឱ្យការបោះពុម្ពផ្សាយ។[44] តាមរយៈសកម្មភាពរបស់ ក.ស.វ. ការសិក្សានានាត្រូវបានធ្វើឡើងយ៉ាងច្រើន ក៏ប៉ុន្តែការបោះពុម្ពចែកផ្សាយជាសាធារណៈ នៅមានលក្ខណៈមិនទាន់ទូលំទូលាយនៅឡើយ ព្រោះតែបញ្ហាថវិកាដែល នៅមានកម្រិតទាបនៅឡើយ ដែលជាហេតុនាំទៅរកនូវកង្វះព័ត៌មានរបស់សាធារណៈជន។ ប៉ុន្តែចំពោះសាធារណៈជន ដែលអាចប្រើប្រាស់បាននូវបច្ចេកវិទ្យាទំនើប និងបណ្ដាញអ៊ីនធឺណេត អាចបើកនូវគេហទំព័ររបស់ ក.ស.វ. បានតាមរយៈអាសយដ្ឋាន www.ecosocc.gov.kh ដើម្បីយល់ច្បាស់ពីព័ត៌មានទាំងឡាយ ក៏ដូចជាការវិភាគពីស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជាផងដែរ។

បញ្ហាប្រឈមមួយទៀតផងដែររបស់ ក.ស.វ. នោះគឺកង្វះនូវការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចដំណើរការ នៃការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តរបស់ ក.ស.វ.។ រាល់លិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញទាំងអស់ គឺសុទ្ធតែមានផលប៉ះពាល់ ដូចនេះការចូលរួមរបស់ប្រជាពលរដ្ឋ គឺពិតជាមានសារៈសំខាន់ ព្រោះថាប្រជាពលរដ្ឋអាចប្រាប់នូវផលវិបាករបស់ខ្លួនប្រសិនបើការអនុវត្តនូវគតិយុត្តទាំងនោះត្រូវបានធ្វើឡើង ហើយប្រការនេះក៏ផ្ដល់ឱកាសឱ្យ ក.ស.វ. ក៏ដូចជាក្រសួងដែលស្នើគតិយុត្តទាំងនោះ ធ្វើការសិក្សាជាថ្មី ដើម្បីធ្វើយ៉ាងណាឱ្យផលប៉ះពាល់ទាំងនោះត្រូវបានកាត់បន្ថយ មកនៅត្រឹមកម្រិតអប្បបរមាមួយដែលគ្រប់ភាគីទាំងអស់អាចទទួលយកបាន ពិសេសគឺភាគីប្រជាពលរដ្ឋតែម្ដង។

### ៣.៣. ដំណោះស្រាយ

ក្រោយពីធ្វើការវិភាគស្វែងរកនូវបញ្ហាប្រឈមនានា នៅក្នុងការអនុវត្តការងារនេះរួចមកការផ្ដល់ជាដំណោះស្រាយ ចំពោះបញ្ហាទាំងនោះគួរតែត្រូវបានធ្វើឡើង ដើម្បីធ្វើការដោះស្រាយបញ្ហាទាំងឡាយដោយវិជ្ជមាន និងមានប្រសិទ្ធភាពខ្ពស់ផងដែរ។

ក្នុងកិច្ចការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលតម្រូវឱ្យមានការចូលរួមពីបណ្ដាក្រសួងនានាក្នុងការផ្ដល់នូវទិន្នន័យសម្រាប់ការវិភាគនោះ ក.ស.វ. គួរតែបង្កើតឱ្យមានជាការជំរុញលើកទឹកចិត្តឱ្យដល់ក្រសួងនានា ដែលធ្វើការពាក់ព័ន្ធវិស័យក្នុងការផ្ដល់ជាទិន្នន័យនានាឱ្យបានទាន់ពេលវេលា និងមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើយ៉ាងណា ឱ្យសកម្មភាពការងារវិភាគនោះមានលក្ខណៈល្អប្រសើរ និងទាន់ពេលវេលា។

[44] យឹម ណុលសន (អនុប្រធាននៃ ក.ស.វ.) និងង៉ាន់ ភិរុណ (ប្រធានអគ្គលេខាធិការដ្ឋាននៃ ក.ស.វ.), បទសម្ភាសដោយ គៀត ចាន់រដ្ឋា និង ក.អ៊ុង សុគន្ធា, ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ២៦ មិថុនា ២០១៥។

ចំពោះសកម្មភាពការងារកម្មវិធី RIA វិញ ក.ស.វ. ដែលតម្រូវឱ្យធ្វើការងារពាក់ព័ន្ធជាមួយក្រសួងជំនាញនានាផងដែរនោះ គួរតែបន្តបង្កើតជាវគ្គបណ្តុះបណ្តាលខ្លីៗធ្វើយ៉ាងណាឱ្យអ្នកដែលមានសិទ្ធិសម្រេចនៅក្នុងស្ថាប័នទាំងនោះ មានការយល់ច្បាស់នូវអ្វីទៅជាកម្មវិធី RIA ហើយបញ្ចប់នូវភាពរួញរារបស់អ្នកទាំងនោះក្នុងការធ្វើការសហការជាមួយ ក.ស.វ. នៅក្នុងសកម្មភាពការងារកម្មវិធី RIA នេះ។ ម្យ៉ាងវិញទៀត ក.ស.វ. ក៏គួរតែបន្តពង្រឹងតាមរយៈវគ្គបណ្តុះបណ្តាលនានាដើម្បីបន្ថែមនូវសមត្ថភាពរបស់មន្ត្រីក្នុងការធ្វើកិច្ចការងារទាក់ទិនទៅនឹង សកម្មភាពកម្មវិធី RIA ដោយធ្វើយ៉ាងណាឱ្យមន្ត្រីទាំងនោះមានសមត្ថភាពគ្រប់គ្រាន់ និងយល់ដឹងខ្ពស់ពីការងារ RIA ដែលពួកគាត់កំពុងតែបំពេញនោះ។

ដោយឡែកចំពោះបញ្ហាកង្វះខាតនូវថវិកាសម្រាប់បម្រើឱ្យការបោះពុម្ពផ្សាយ ទៅលើស្នាដៃដែល ក.ស.វ. សម្រេចបាន ដើម្បីចែកផ្សាយជាសាធារណៈវិញ ក.ស.វ. គួរតែធ្វើការស្នើសុំថវិកាបន្ថែមពីរាជរដ្ឋាភិបាលកម្ពុជា ដោយដាក់ជាគម្រោងសំណើថវិកា ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ដើម្បីឱ្យរាជរដ្ឋាភិបាលជឿទុកចិត្តថា ប្រសិនបើថវិកាទាំងនោះត្រូវបានផ្តល់ជូនមក ក.ស.វ. នោះគឺពិតជាត្រូវបានប្រើប្រាស់សម្រាប់ ការបោះពុម្ពផ្សាយស្នាដៃទាំងនោះជាសាធារណៈមែន។ ផ្សេងពីនេះទៀត ក.ស.វ. ក៏អាចស្នើសុំទៅសប្បុរសជន ដែលមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការផ្គត់ផ្គង់នូវថវិកាសម្រាប់ជំនួយដល់ការបោះពុម្ពផ្សាយនូវ ស្នាដៃទាំងនោះជាសាធារណៈ ពីព្រោះថាស្នាដៃទាំងនោះមិនមែនត្រឹមតែមានប្រយោជន៍សម្រាប់រាជរដ្ឋាភិបាល ក៏ដូចជា ក.ស.វ. ខ្លួនឯងនោះទេ តែស្នាដៃទាំងនោះពិតជាមានសារៈប្រយោជន៍ដល់សាធារណៈជន ឱ្យបានយល់ដឹងកាន់តែច្រើនពីស្ថានភាពសង្គម ក៏ដូចជាផ្តល់ផលវិជ្ជមានដល់សង្គមជាតិផងដែរ។

នៅក្នុងកង្វះនូវការចូលរួមរបស់ប្រជាពលរដ្ឋវិញ ក.ស.វ. គួរតែធ្វើយ៉ាងណាដើម្បីឱ្យមានជាការបើកទូលាយដល់ ប្រជាពលរដ្ឋសម្រាប់ការចូលរួម ឱ្យបានជាអតិបរមានៅក្នុងសកម្មភាពទាំងឡាយដែល ក.ស.វ. បាននឹងកំពុងធ្វើនាពេលបច្ចុប្បន្ននេះ។ ការចូលរួមនេះ ក.ស.វ. អាចធ្វើឡើងតាមរយៈការអនុញ្ញាតឱ្យពលរដ្ឋជ្រើសតាំងនូវតំណាងរបស់ពួកគាត់ ដើម្បីចូលរួមឱ្យខានតែបាននៅក្នុងដំណើរការងារទាំងនោះ។ នៅពេលដែលពលរដ្ឋបាន ចូលរួមនៅក្នុងដំណើរនៃការងារផ្សេងៗរបស់ ក.ស.វ. ពេលនោះពលរដ្ឋអាចផ្តល់ជាមតិយោបល់នានាទៅកាន់ ក.ស.វ. ដើម្បីកែសម្រួល ឬបន្ថែមនូវចំណុចនានាដែលមានការខ្វះខាតហើយដែល ក.ស.វ. បានអនុវត្តនៅក្នុងសកម្មភាពរបស់ខ្លួនដើម្បីឈានទៅរកភាពល្អប្រសើររបស់ ក.ស.វ. ទៅលើផ្នែកការងារផង និងដើម្បីប្រយោជន៍របស់ប្រជាពលរដ្ឋខ្លួនឯងផង ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវជាហូរហែររួចមក ការសិក្សាដែលបានធ្វើឡើងនេះបានបកស្រាយនូវចំណុចជាច្រើនដែលក្នុងនោះរួមមាន ជំពូកទី ១ ដែលបានធ្វើការសិក្សាអំពីគោលការណ៍ទូទៅនៃអភិបាលកិច្ចល្អ ដែលជាទ្រឹស្តីយ៉ាងសំខាន់មួយនៅក្នុង ការជំរុញឱ្យមានភាពល្អប្រសើរនៅក្នុងការអនុវត្តនូវកិច្ចការងារទាំងឡាយ ដែលក្នុងនោះមានដូចជា ការសិក្សាទៅលើនិយមន័យនៃទ្រឹស្តីអភិបាលកិច្ចល្អ ដែលបានផ្តល់នៅក្នុងវចនានុក្រមខ្មែរ ផ្តល់ដោយរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃធនាគារពិភពលោក និងអង្គការសហប្រជាជាតិនៃកម្មវិធីអភិវឌ្ឍន៍។ ក្នុងនោះគោលការណ៍នៃអភិបាលកិច្ចល្អចំនួនបី ត្រូវបានលើកយកមកពិភាក្សា ដែលក្នុងនោះរួមមានគោលការណ៍នៃអភិបាលកិច្ចល្អរបស់ រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងធនាគារពិភពលោក។ លើសពីនេះទៅទៀតនៅក្នុងជំពូកទី ២ នៃការសិក្សាស្រាវជ្រាវនេះ ក៏បានពិពណ៌នាអំពីប្រវត្តិនៃការកើតឡើងនូវក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលក្នុងនោះបានរាប់បញ្ចូលតាំងពីការកកើតដំបូងរហូតមកដល់ពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត នៅក្នុងជំពូកទី ២ នេះដែរក៏ធ្វើការសិក្សាអំពីសមត្ថកិច្ចនិងភារកិច្ចរបស់ ក.ស.វ. និងមុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ ក.ស.វ. ដែលក្នុងនោះត្រូវបានសិក្សាបែងចែកជាផ្នែកលម្អិតហើយដែលក្នុងនោះរួមមាន ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ ផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ផ្នែកវិភាគ និងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ផ្នែកសិក្សាស្រាវជ្រាវ និងអង្កេត ផ្នែកលិខិតបទដ្ឋានគតិយុត្ត ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន និងផ្នែកទំនាក់ទំនង និងកិច្ចសហការអន្តរជាតិ។ ផ្សេងពីនេះទៀត ក្នុងការសិក្សានេះក៏ធ្វើឡើងទៅលើសមិទ្ធផល និងស្នាដៃនានាដែល ក.ស.វ. សម្រេចបានព្រមទាំងលទ្ធផលនៃការវិភាគទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយរាប់ទាំងទស្សនៈវិស័យរបស់ ក.ស.វ. នៅពេលអនាគតផងដែរ។ ជាចំណុចចុងក្រោយនៃការសិក្សានេះផងដែរគឺ ជំពូកទី ៣ ដែលបានធ្វើការសិក្សា និងវិភាគទៅលើការអនុវត្តការងាររបស់ ក.ស.វ. ក្នុងពេលកន្លងមកហើយដែលត្រូវបានធ្វើឡើងតាមរយៈការយកនូវគោលការណ៍ទាំងឡាយនៃអភិបាលកិច្ចល្អ របស់ក្រសួងមហាផ្ទៃ ដែលជាគោលការណ៍ចម្បងនៃការសិក្សាប្រធានបទនេះយកមកវិភាគ និងស្វែងរកនូវបញ្ហាប្រឈមនានាដោយផ្តល់ជាដំណោះស្រាយផ្សេងៗ ប្រកបដោយលក្ខណៈវិជ្ជមានដើម្បីធ្វើការដោះស្រាយនូវបញ្ហាប្រឈមទាំងនោះប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងគោលការណ៍នៃអភិបាលកិច្ចល្អផងដែរ។

ជារួមតាមរយៈកិច្ចការដែលបានធ្វើការវិភាគសិក្សាស្រាវជ្រាវនេះ បានបង្ហាញឱ្យឃើញថា ទ្រឹស្តីអភិបាលកិច្ចល្អ នៅតែជាទ្រឹស្តីមួយដែលមានលក្ខណៈល្អពិសេស សម្រាប់ធ្វើឱ្យសកម្មភាពនៃអង្គភាព ឬស្ថាប័នមួយ មានលក្ខណៈល្អប្រសើរក្នុងការអនុវត្តការងារ ក៏ដូចជាសម្រាប់ការធ្វើផែនការការងារផ្សេងៗផងដែរ។ បន្ថែមពីនេះទៀតតាមរយៈគោលការណ៍នៃអភិបាលកិច្ចល្អ ដែលបានដាក់ចេញដោយស្ថាប័ននានា ត្បិតតែមានភាពខុសគ្នាទៅលើគោលការណ៍មួយចំនួន ដោយរាប់ទាំងការប្រើប្រាស់ពាក្យពេចន៍ជាដើម ប៉ុន្តែគោលការណ៍ទាំងនោះសុទ្ធតែអាចប្រើប្រាស់បានសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវកិច្ចការដែលបានកំពុងអនុវត្ត ក៏ដូចជាសកម្មភាពការងារនៅពេលខាងមុខរបស់អង្គភាព ឬស្ថាប័នមួយផងដែរ។ ដោយមើលឃើញថា ក.ស.វ. ជាក្រុមប្រឹក្សាដែលទើបតែបង្កើតឡើងនៅឆ្នាំ ២០០៩ ហើយពុំទាន់មានការស្រាវជ្រាវណាបានធ្វើឡើងពាក់ព័ន្ធទៅដល់ការអនុវត្តកិច្ចការងារ និងសកម្មភាពដែលក្រុមប្រឹក្សានេះបានធ្វើ និងកំពុងធ្វើ ហេតុនេះហើយបានជាការស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ សម្រាប់ការស្វែងយល់ ក៏ដូចជាវិភាគទៅលើការអនុវត្តការងាររបស់ ក.ស.វ. នេះ។

ជាលទ្ធផល បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ព្រមទាំងវិភាគទៅលើប្រធានបទទាំងមូលរួចមក ការសន្និដ្ឋានជាចុងក្រោយអាចនិយាយជារួមបានថា ការអនុវត្តកិច្ចការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ពិតជាបានធ្វើដំណើរស្របតាមគោលការណ៍ទាំងឡាយនៃទ្រឹស្តីអភិបាលកិច្ចល្អ របស់ក្រសួងមហាផ្ទៃ បើទោះបីជាក្រុមប្រឹក្សានេះទើបតែត្រូវបានបង្កើតនាពេលថ្មីៗនេះក៏ដោយ។ ជាពិសេសទៅទៀតនោះតាមរយៈសកម្មភាពនានាដែលក្រុមប្រឹក្សានេះបានធ្វើឡើងដូចជាការវិភាគទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជា ក៏ដូចជា កម្មវិធី RIA ជាដើមគឺសុទ្ធតែជាសកម្មភាព ដែលមានលក្ខណៈបម្រើឱ្យផលប្រយោជន៍នៃសង្គមជាតិក៏ដូចជាបានផ្តល់នូវព័ត៌មានដល់ពលរដ្ឋក្នុងសង្គម ឱ្យបានយល់ដឹងពីការវិវត្តរបស់ប្រទេសជាតិជាដើម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅក្នុងកិច្ចការវិភាគស្រាវជ្រាវនេះ បានរំលេចចេញនូវបញ្ហានានាដែលក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានជួបប្រទះនៅក្នុងដំណើរការការងាររបស់ខ្លួនដែលក្នុងនោះរួមមានដូចជា ការមិនចូលរួមសហការឱ្យបានជិតដល់ពីបណ្តាក្រសួងនានាដែលមានជំនាញពាក់ព័ន្ធក្នុងវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងការផ្តល់ជាទិន្នន័យទាំងឡាយដល់ក្រុមប្រឹក្សា សម្រាប់បម្រើឱ្យការវិភាគឱ្យទាន់ពេលវេលា និងបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ។ មួយវិញទៀតកង្វះនូវការយល់ដឹងរបស់អ្នកពាក់ព័ន្ធក្នុងគម្រោង RIA នៅតែជាបញ្ហាមួយដែលចោទឡើងសម្រាប់ការអនុវត្តការងារនៃគម្រោង RIA បើទោះបីជាគម្រោងនេះត្រូវបានអនុវត្តប្រកបដោយភាពជោគជ័យយ៉ាងណាក៏ដោយ។ បន្ថែមពីនេះទៀតកង្វះនូវឱកាសសម្រាប់បម្រើ

ឱ្យការបោះពុម្ពផ្សាយ ក៏ជាបញ្ហាមួយក្នុងការរាំងស្ទះចំពោះការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃនៃការវិភាគ ក៏ដូចជាសកម្មភាពការងារនានាដែល ក.ស.វ. បានធ្វើ ទៅកាន់សាធារណៈជនទាំងឡាយឱ្យមានការយល់ដឹងក្នុងកម្រិតខ្ពស់មួយ។ បញ្ហាប្រឈមមួយទៀតផងដែរនោះគឺការមិនបានចូលរួមដោយផ្ទាល់ និងមិនផ្ទាល់ របស់ប្រជាពលរដ្ឋនៅក្នុង ដំណើរការការងារមួយចំនួនរបស់ ក.ស.វ. ដែលមានការពាក់ព័ន្ធដល់ពួកគាត់ ព្រោះថានៅពេលដែល អវត្តមានប្រជាពលរដ្ឋបានកើតឡើង លទ្ធផលការងារ ឬសកម្មភាពមួយចំនួនអាចនឹងមិនបម្រើឱ្យប្រយោជន៍របស់ប្រជាពលរដ្ឋដែលចង់បាន ឬមានផលប៉ះពាល់ទៅលើប្រជាពលរដ្ឋជាដើម។

ជាចុងក្រោយតាមរយៈកិច្ចការវិភាគស្រាវជ្រាវនេះបានឆ្លុះបញ្ចាំង និងបានបង្ហាញឱ្យឃើញច្បាស់នូវការអនុវត្តកិច្ចការងាររបស់ ក.ស.វ. ស្របទៅតាមគោលការណ៍ និង ទ្រឹស្តីអភិបាលកិច្ចល្អ ដែលធ្វើឱ្យដំណើរការការងាររបស់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នេះមានភាពលេចធ្លោជាច្រើននៅក្នុងសកម្មភាពការងារដែលកំពុងធ្វើ និងនៅតែបន្តធ្វើនាពេលខាងមុខ។ ឆ្លើយតបទៅនឹងចំណុចល្អៗដែលបានធ្វើស្របទៅតាមគោលការណ៍អភិបាលកិច្ចល្អ និងបញ្ហាប្រឈមនានាដែលក្រុមប្រឹក្សាបានជួបប្រទះ យើងខ្ញុំដែលជាអ្នកស្រាវជ្រាវនូវកិច្ចការមួយនេះមានក្តីសង្ឃឹមនិងជឿជាក់ថា កិច្ចការសារណាបញ្ចប់ការសិក្សានេះ នឹងក្លាយទៅជាឯកសារគន្លឹះមួយសម្រាប់ឱ្យនិស្សិត ឬអ្នកសិក្សាទាំងឡាយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមផង និងបន្តការសិក្សាវិភាគបន្ថែមទៅលើចំណុចនានានៃសារណានេះ។ ជាពិសេសនោះកិច្ចការនេះ ក៏អាចជាគន្លឹះមួយសម្រាប់ឱ្យ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ យកទៅពិចារណាសម្រាប់ធ្វើការកែតម្រូវនូវចំណុចនានាដែលមានការខ្វះខាត និងដើម្បីធ្វើឱ្យការអនុវត្តកិច្ចការងាររបស់ក្រុមប្រឹក្សាទាំងមូល មានភាពកាន់តែ ល្អប្រសើរឡើងៗ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការសង្គមផងដែរ។

## ២. អនុសាសន៍

អនុសាសន៍មួយចំនួន ក៏ត្រូវបានផ្តល់ជូនដល់ ក.ស.វ. សម្រាប់ធ្វើការសិក្សាបន្ថែមដើម្បីធ្វើការកែប្រែ និងដើម្បីភាពប្រសើរឡើងនៃដំណើរការការងាររបស់ ក.ស.វ. ដែលរួមមានដូចជាៈ

ក. ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គួរមានយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀតដើម្បីធ្វើឱ្យសាធារណៈជនបានស្គាល់ពីក្រុមប្រឹក្សានេះឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

ខ. ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គួរតែបង្កើននូវកិច្ចសហការជាមួយអង្គការជាតិ និងអន្តរជាតិនានាបន្ថែមទៀតដើម្បី ធ្វើឱ្យដំណើរការកិច្ចការងាររបស់ខ្លួនមានភាពកាន់តែល្អប្រសើរបន្ថែមទៅលើអ្វីដែលមានភាពល្អប្រសើរស្រាប់។

គ. ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គួរតែធ្វើយ៉ាងណាឱ្យ ស្នាដៃដែលខ្លួនបានខិតខំបំពេញ បានទៅដល់ដៃរបស់សាធារណៈជនទាំងឡាយ ឱ្យបានទាន់ពេលវេលាដោយរាប់ទាំងឯកសារបោះពុម្ព ក៏ដូចជាឯកសារអេឡិចត្រូនិច ដែលអាចស្វែងរកបាននៅលើគេហទំព័រផ្លូវការរបស់ ក.ស.វ. ផ្ទាល់តែម្តង។

# ឯកសារយោង


-ព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ នស/រកត/០២០៩/១៧៣, ១៧ កុម្ភៈ ២០០៩។

-អនុក្រឹត្យស្តីពី ការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ០៥អនក្រ/តត, ១១ មករា ១៩៩៩។

-អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, លេខ៤៥អនក្រ/បក, ០៣ មីនា ២០០៩។

-ក្រសួងមហាផ្ទៃ. ២០១០. *អភិបាលកិច្ចល្អ.* ភ្នំពេញ។

-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌. ២០១៤. *ព្រឹត្តិបត្រព័ត៌មាន សកម្មភាពការងារ*. ឆ្នាំទី ០៧ លេខ ១២។

-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌. ២០១៤. *ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌.* ភ្នំពេញ។

-ជួន ណាត. ១៩៦៧. *វចនានុក្រមខ្មែរ.* ភ្នំពេញ៖ បណ្ណាគារពុទ្ធសាសនបណ្ឌិត្យ។

-រាជរដ្ឋាភិបាលកម្ពុជា. ២០១៣. *យុទ្ធសាស្រ្តចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា.* ភ្នំពេញ។

-IFAD. 1999. *Good Governance: An Overview* [អភិបាលកិច្ចល្អ៖ ទិដ្ឋភាពទូទៅ]. Rome. www.ifad.org/gbdocs/eb/67/e/EB-99-67-INF-4.pdf (ថតចម្លងថ្ងៃទី ២៥ មេសា ២០១៥) ។